**OMI0015**

# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ អ៊ឹម ឡុត ភេទប្រុស អាយុ៥៧ឆ្នាំ**

**មុខងារជំនាន់ខ្មែរក្រហមៈ“យោធាការពារព្រំដែនខ្មែរ-ថៃ”**

**សព្វថ្ងៃនៅភូមិអូរគគីរក្រោម ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០១:៤៩:០៧**

**៤៨ទំព័រ**

ដានីៈ ចឹងមុននិងខ្ញុំចាប់ផ្ដើមសួរនាំលោកពូ ខ្ញុំចង់ណែនាំខ្លួនខ្ញុំមួយសារទៀតប្រាប់លោកពូឲ្យកាន់តែច្បាស់លោកពូ ពួកខ្ញុំ៥នាក់នេះមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាខ្ញុំឈ្មោះ ដានី គាត់ឈ្មោះ លក្ខិណា ហើយនេះឈ្មោះ វណ្ណៈ ហើយពីរនាក់ទៀតឈ្មោះ ធានី និង ពិចិត្រ គាត់ទៅជួបប្រជាជនដែរ ពួកខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជានៅទីក្រុងភ្នំពេញ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាសមាជិកមួយនៃគណកម្មាធិការអន្តរក្រសួងដែលរដ្ឋាភិបាលបង្កើតឡើងដើម្បីអភិវឌ្ឍន៍នៅតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រក្នុងស្រុកអន្លង់វែងយើង ហើយខាងមជ្ឈមណ្ឌលឯកសារកម្ពុជាខាងខ្ញុំនេះមានភារកិច្ចជាអ្នករៀបចំចងក្រងនិងប្រមូលឯកសារនិងសរសេរសៀវភៅប្រវត្តិសាស្ត្រនិងសៀវភៅទេសចរណ៍នៅក្នុងស្រុកអន្លង់វែង ហើយការដែលប្រមូលឯកសារសរសេរសៀវភៅនេះគឺវាផ្សារភ្ជាប់ជាមួយជីវិតបងប្អូនប្រជាពលរដ្ឋយើងដែលគាត់រស់នៅក្នុងតំបន់អន្លង់វែងទាំងមូល ជាពិសេសនៅក្នុងគ្រប់ភូមិគ្រប់ឃុំក្នុងស្រុកអន្លង់វែងយើង ការដែលសរសេរនេះបានអាស្រ័យទៅលើបងប្អូនប្រជាពលរដ្ឋគាត់ចែករំលែកបទពិសោធន៍ជីវិតរបស់គាត់ ដែលបានឆ្លងកាត់តាំងពីសម័យសង្គ្រាមរហូតដល់សមាហរណកម្មឆ្នាំ៩៨ យើងរស់នៅតាមស្រុកតាមភូមិប្រកបមុខរបររកស៊ីតាមរៀងៗខ្លួន ហើយខ្ញុំមកភូមិលោកពូមកជួបជាមួយលោកពូ និងបងប្អូនប្រជាពលរដ្ឋនៅក្នុងភូមិលោកនេះ គឺគោលបំណងចង់ដឹងពីបទពិសោធន៍ ជីវិតរស់នៅរបស់លោកពូ មីងអ៊ំ តាយាយម្នាក់ៗថាបានឆ្លងកាត់មកជីវិតយ៉ាងម៉េចខ្លះ ហេតុអីបានជាចាប់ផ្ដើមជីវិតនៅអន្លង់វែង ពីព្រោះបើតាមបទពិសោធន៍ដែលខ្ញុំចុះមកប៉ុន្មានខែកន្លងមកនេះ ខ្ញុំឃើញថាអ៊ំពូមីងមកពីខេត្តផ្សេងៗគ្នា មកពីស្រុកភូមិផ្សេងៗគ្នា ស្ទើរតែទូទាំងប្រទេស ដែលមករស់នៅអន្លង់វែង ចឹងហើយបទពិសោធន៍របស់អ៊ំម្នាក់ៗហ្នឹង គឺវាមានសារសំខាន់មែនទែន

យកទៅសរសេរទៅចងក្រងហ្នឹង ហើយខ្ញុំជួបលោកពូនេះ គឺចង់ដឹងពីជីវិតរបស់លោកពូ ដែលបានឆ្លងកាត់មកតាំងពីក្មេងរហូតមក ឆ្លងកាត់សម័យសង្គ្រាមទី១ទី២រហូតដល់យើង សមាហរណកម្ម ហើយយើងសម្រេចចិត្តថាយើងរស់នៅទីនេះ ប្រកបរបររកស៊ីតាម គ្រួសារតាមស្រុកភូមិ នៅអូរគគីរក្រោមនេះលោកពូ ។

ឡុតៈ បាទ ។

ដានីៈ ចឹងលោកពូអនុញ្ញាតឲ្យខ្ញុំសួរនាំទាក់ទងនិងជីវិតរបស់ពូដែលទេ?

ឡុតៈ សួរចុះខ្ញុំអ្នកឆ្លើយ ។

ដានីៈ ចឹងដំបូងខ្ញុំចង់ស្គាល់ឈ្មោះ លោកពូពេញ ពូឈ្មោះអីដែរ?

ឡុតៈ អ៊ុំម ឡុត ។

ដានីៈ ពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

ឡុតៈ ៥៧ ។

ដានីៈ ៥៧ឆ្នាំកើតឆ្នាំអីដែលឆ្នាំខ្មែរយើង?

ឡុតៈ ឆ្នាំរកា ។

ដានីៈ កំណើតកេតជានៅក្នុងភូមិឃុំអីដែលលោកពូ?

ឡុតៈ ភូមិបុស្សធំ ឃុំស្នួល ស្រុកក្រឡាញ់ ខេត្តសៀមរាប ។

ដានីៈ ចុះសព្វថ្ងៃនៅក្នុងភូមិឃុំស្រុកអីដែរ?

ឡុតៈ ភូមិអូរគគីក្រោម ឃុំលំទង ស្រុកអន្លង់វែង ។

ដានីៈ ខេត្ត?

ឡុតៈ ខេត្តឧត្តរមានជ័យ ។

ដានីៈ គ្រួសារលោកពូគាត់ឈ្មោះអីដែរ?

ឡុតៈ ឈ្មោះ សៅ យឹម ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

ឡុតៈ គាត់អាយុ៥៤ ។

ដានីៈ គាត់អ្នកស្រុកកំណើតនៅណាដែរ?

ឡុតៈ ភូមិកំណើតនៅភូមិតាអុង ឃុំល្វែងឫស្សី ស្រុកជីក្រែង ។

ដានីៈ ល្វែងឫស្សី ស្រុកជីក្រែង ខេត្តសៀមរាប?

ឡុតៈ បាទ! តែមួយនៅកើតមួយនៅលិច ។

ដានីៈ លោកពូមានកូនចៅប៉ុន្មាននាក់ហើយសព្វថ្ងៃ?

ឡុតៈ មានកូន៦នាក់ ។

ដានីៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ឡុតៈ ស្រី៥ ប្រុស១ ។

ដានីៈ ធំៗអស់ហើយ?

ឡុតៈ មានប្ដីអស់ខ្លះហើយ ។

ដានីៈ នៅសល់ពីរនាក់?

ឡុតៈ បាទ ។

ដានីៈ ពូប្រកបរបររកស៊ីអីដែរ?

ឡុតៈ ធ្វើស្រែ ។

ដានីៈ ហើយលោកពូធ្វើជាមេភូមិអូរគគីរក្រោមនេះតាំងពីពេលណាមក?

ឡុតៈ តាំងពី៩៩មក ។

ដានីៈ លោកពូឪពុកលោកពូឈ្មោះអីដែរ?

ឡុតៈ ឈ្មោះ អ៊ឹម ធៀម ។

ដានីៈ សព្វថ្ងៃគាត់នៅរស់ ឬស្លាប់ហើយ?

ឡុតៈ គាត់ស្លាប់យូរហើយ ។

ដានីៈ គាត់ស្លាប់ហើយ គាត់ស្លាប់នៅណា?

ឡុតៈ គាត់ស្លាប់នៅស្រុកកំណើត ។

ដានីៈ តាំងពីជំនាន់ណាទៅ?

ឡុតៈ តាំងពី៨៣ ។

ដានីៈ ចឹងម្ដាយលោកពូឈ្មោះអីដែរ?

ឡុតៈ ម្ដាយឈ្មោះ ហ៊ឹម ឡាប ។

ដានីៈ សព្វថ្ងៃគាត់នៅរស់ ឬស្លាប់ហើយនៅ?

ឡុតៈ គាត់ស្លាប់អស់ហើយ ។

ដានីៈ គាត់ស្លាប់តាំងពីឆ្នាំណាទៅ?

ឡុតៈ ម៉ែស្លាប់ឆ្នាំ៩៤ ។

ដានីៈ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

ឡុតៈ មាន៥នាក់ ។

ដានីៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ឡុតៈ ស្រី៣ប្រុស២ ។

ដានីៈ ហើយលោកពូកូនទីប៉ុន្មានទៅ?

ឡុតៈ កូនទី៤ ។

ដានីៈ លោកពូកាលពីក្មេងៗលោកពូបានរៀនសូត្រអីដល់ណាដែរ?

ឡុតៈ បានត្រឹមថ្នាក់ទី៧ ។

ដានីៈ នៅសាលាណាទៅ?

ឡុតៈ នៅសាលាក្រឡាញ់ ។

ដានីៈ ទី៧ចាស់កាលហ្នឹង?

ឡុតៈ បាទ ។

ដានីៈ ពូរៀនបានច្រើនដែលសាលាក្រឡាញ់ហ្នឹងគេហៅសាលាស្អីគេដូចជាវិទ្យាល័យក្រឡាញ់ ឬ អនុវិទ្យាល័យក្រឡាញ់?

ឡុតៈ បឋមសិក្សាទី៧ពីដើមមិនទាន់ចូលអនុវិទ្យាល័យទេ ។

ដានីៈ ចឹងថ្នាក់ទី៧ពីដើមមិនចូលទេ?

ឡុតៈ បាទ ។

ដានីៈ ចឹងនៅបឋមសិក្សា?

ឡុតៈ បឋមសិក្សាបំពេញវិជ្ជាក្រឡាញ់គេដាក់ចឹង ។

ដានីៈ នៅជិតផ្ទះដែលសាលា?

ឡុតៈ ទេ ឆ្ងាយខ្ញុំទៅនៅវត្ត ។

ដានីៈ ចឹងស្នាក់នៅវត្តអីគេ?

ឡុតៈ នៅវត្តក្រឡាញ់ ។

ដានីៈ រៀនពីឆ្នាំណាដល់ឆ្នាំណាទៅ?

ឡុតៈ ខ្ញុំមិនបានចាំទេ ចាំតែឆ្នាំឈប់នៅឆ្នាំ៧០ ដែល លន់ នល់ ធ្វើរដ្ឋប្រហារសម្តេចសីហនុ ។

ដានីៈ ចឹងកាលពីក្មេងៗលោកពូស្រមៃចង់រៀបសូត្រដល់ណា ចង់ធ្វើអីដែលកាលយើងកំពង់តែសិក្សា?

ឡុតៈ ទេ កាលហ្នឹងមិនទាន់មានគោលបំណងអីទេ ចង់តែរៀនឲ្យចេះដើម្បីសម្រាប់រកស៊ីទោះបីធ្វើស្រែចម្ការក៏បានចេះបានដឹងគេខ្លះដែរ ព្រោះជាកូនអ្នកក្រ ។

ដានីៈ ចឹងលោកពូកាលហ្នឹងអត់មានគិតថា ចង់រៀនឲ្យបានខ្ពស់ដើម្បីយើងចាប់យកអាជីពស្អីមួយអត់ដែលមានគិតចឹងទេ?

ឡុតៈ អត់ទេ កាលនោះខ្ញុំនៅតូចដែរ ឈប់រៀនអាយុ១៥ឆ្នាំ ។

ដានីៈ កាលហ្នឹងលោកអាន សរសេរស្ទាត់ជំនាញហើយនៅ?

ឡុតៈ បាទ! កាលហ្នឹងចេះ ដល់ឈប់យូរចេះទៅក៏វាភ្លេច ។

ដានីៈ ចឹងកាលហ្នឹងចេះភាសាបារាំងខ្លះៗដែលអត់?

ឡុតៈ កាលហ្នឹងចេះបារាំងសព្វថ្ងៃភ្លេចអស់ហើយ វានៅចាំតួអក្សរមួយដែរ តែឲ្យអានឲ្យប្រកបអី វាអត់បានទេ យើងចោលវាយូរហើយ ។

ដានីៈ ចឹងលោកឈប់ឆ្នាំ៧០ហើយមកធ្វើអីទៀតទៅ?

ឡុតៈ ធ្វើស្រែ ។

ដានីៈ មកនៅជាមួយឪពុកម្ដាយវិញ?

ឡុតៈ បាទ ។

ដានីៈ ធ្វើស្រែបានប៉ុន្មានឆ្នាំទៅ?

ឡុតៈ ឆ្នាំ៧០ដល់៧៣ខ្ញុំចូលទ័ព ។

ដានីៈ ចឹងឆ្នាំ៧៣ចូលធ្វើកងទ័ព?

ឡុតៈ បាទ ។

ដានីៈ ចឹងកាលឆ្នាំ៧៣ចូលធ្វើកងទ័ពហ្នឹង កាលហ្នឹងយ៉ាងម៉េចពូនៅចាំរៀបរាប់ថា ឆ្នាំ៧៣ហ្នឹង មានព្រឹត្តិការណ៍អ្វី មានមូលហេតុអីបានជាលោកពូចូលកងទ័ព?

ឡុតៈ កាលនោះដូចថា លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចសីហនុទៅ ខាងខ្ញុំត្រូវខ្មែរក្រហម កាន់កាប់ចឹងទៅមានការរើសទ័ពចូលវាយ លន់ នល់ កាលនោះ ។

ដានីៈ ចឹងភូមិក្រឡាញ់ភូមិស្រុកកំណើតរបស់ពូហ្នឹងត្រូវខាងខ្មែរក្រហមគ្រប់គ្រងតាំងពីឆ្នាំណា?

ឡុតៈ ឆ្នាំ៧០ហ្នឹងឯង ។

ដានីៈ តាំងពី៧០មក?

ឡុតៈ ៧០កាលនោះវាមានវៀតណាម កាលពីដើមមិញគេហៅវៀតកុង ចុះមកជួយខាងសម្ដេច សីហនុ ជួយពង្រឹងខ្មែរក្រហម កាលហ្នឹងហៅបដិវត្តរណសិរ្សគេនោះណាស់ ។

ដានីៈ ចឹងកាលហ្នឹងខាងខ្មែរក្រហមគេគ្រប់គ្រងតាំងពី លន់ នល់ ធ្វើរដ្ឋប្រហាឆ្នាំ៧០ហើយនៅ ស្រុកខាងខ្មែរក្រហមគ្រប់គ្រង?

ឡុតៈ បាទ! នៅជនបទខាងខ្មែរក្រហមគ្រប់គ្រង ។

ដានីៈ ចឹងដល់ឆ្នាំ៧២លោកពូស្ម័គ្រចូលកងទ័ពខ្មែរក្រហម ឬមានគេមកជ្រើសរើស គេតម្រូវឲ្យ យើងចូល?

ឡុតៈ គេជ្រើសរើសតាមភូមិហ្នឹងឯង តែខ្ញុំស្ម័គ្រចិត្តបណ្ដោយ នឹកឃើញថាស្រុកសង្គ្រាមវាត្រូវតែធ្វើទៅហើយ ។

ដានីៈ ចឹងលោកពូពេលលោកស្ម័គ្រចិត្តដំបូងយើងទៅធ្វើអីនៅកន្លែងណាទៅ?

ឡុតៈ ស្ម័គ្រចិត្តទៅគេបញ្ជូនទៅសាលាយោធាហាត់យោធាចេញមកវិញទៅកាន់សមរភូមិ ។

ដានីៈ លោកពូទៅហាត់បច្ចេកទេសកងទ័ពហ្នឹងអស់រយៈពេលប៉ុន្មាននៅណា?

ឡុតៈ ហាត់កាលនោះមួយខែហាត់នៅភ្នំបូក តាឯកនេះ ។

ដានីៈ ភ្នំបូករន្ធតាឯកខាងបាត់ដំបងវិញ?

ឡុតៈ អត់ទេ ខាងត្បូងប្រដាកខាងកើតអង្គរយើងហ្នឹង ។

ដានីៈ ហាត់យ៉ាងម៉េចខ្លះទៅមួយខែហ្នឹង?

ឡុតៈ ហាត់លូនហាត់ក្រាប បចេកទេសយោធា បច្ចេកទេសសម្រុកវាយនេះមួយចប់ ។

ដានីៈ មានគ្នាច្រើនទេទៅហាត់ហ្នឹង?

ឡុតៈ មួយជំនាន់ខ្ញុំមាន៣០០នាក់ ។

ដានីៈ ដល់ពេលយើងហាត់មួយខែហើយគេបញ្ជូនទៅណាទៅ?

ឡុតៈ គេបែកមកតាមអង្គភាព ។

ដានីៈ លោកពូនៅអង្គភាពណា?

ឡុតៈ កាលនោះខ្ញុំវាអត់ស្គាល់លេខកងពលដែលទេ ចាំបានតែលេខវរសេនាតូច៩០៥ ។

ដានីៈ វរសេនាតូចរបស់ពីណា៩០៥ហ្នឹង?

ឡុតៈ កាលនោះប្រធានវរៈហ្នឹងឈ្មោះ តា ភា អ្នកមកពីកំពង់ចាម ។

ដានីៈ ចឹងតា ភា ហ្នឹងគាត់ជាអ្នកកំពង់ចាម?

ឡុតៈ បាទ ។

ដានីៈ វរៈហ្នឹងឈរជើងនៅណា?

ឡុតៈ ឈរជើងចាប់ពីកែងបារាយណ៍ មកទល់ជ្រោយល្វស្រុកស្រីស្នំដាក់ស្រីស្នំទៅ ។

ដានីៈ តាំងពីកែងបារាយណ៍មកទល់ស្រីស កាលហ្នឹងនៅក្នុងកងពលពីណាគេ?

ឡុតៈ អត់ស្គាល់ទេ កាលនោះដឹងថាឈ្មោះ តា លន់ៗ ទទួលរួម ។

ដានីៈ តា ឡុញ?

ឡុតៈ តា លន់ ។

ដានីៈ ចឹងតា លន់ គាត់ទទួលរួម?

ឡុតៈ បាទ! ទទួលមួយខេត្តសៀមរាប កាលនោះមិនទាន់ស្គាល់កងពលអីទេ កាលនោះស្គាល់តែលេខវរសេនាតូចវៀងៗខ្លួនកាលនោះ ។

ដានីៈ កាលហ្នឹងនៅក្នុងខេត្តសៀមរាបនៅក្នុងតំបន់អីទៅ កាលពីលោកពូចូលកងទ័ព?

ឡុតៈ កាលនោះសៀមរាបគេហៅតំបន់ប៉ុន្មាន តំបន់៣៥ ខេត្តសៀមរាបតំបន់៣៥ ភូមិភាគ៤ ។

ដានីៈ ភូមិភាគ៤ ឬភូមិភាគ៣០៤?

ឡុតៈ អះ!៣០៤ហ្នឹងឯង កាលនោះហៅតែកាត់ ។

ដានីៈ ភូមិភាគ៣០៤នៅខាងណាវិញ?

ឡុតៈ ភូមិភាគ៣០៤មានកំពង់ចាម កំពង់ធំ សៀមរាប កាលហ្នឹង ។

ដានីៈ ចឹងឧត្តរមានជ័យព្រះវិហារអត់ទេ?

ឡុតៈ ឧត្តរមានជ័យចូលចំណុះខេត្តសៀមរាបកាលនោះគេមិនទាន់លកាត់ទេ ខាងព្រះវិហារដូចជាតំបន់ដោយឡែកផ្សេង ។

ដានីៈ តំបន់ដោយឡែកផ្សេង តំបន់ប៉ុន្មានទៅកាលហ្នឹង?

ឡុតៈ អត់ចាំ ។

ដានីៈ ចឹងកាលហ្នឹងគណៈតំបន់៣៥ពីណាគេ?

ឡុតៈ តា ហ៊ាន ។

ដានីៈ តា ហ៊ាន ហ្នឹងគាត់គណៈតំបន់ គាត់ទទួលខាងកងទ័ព ឬអត់ទេ?

ឡុតៈ ទេ ខ្ញុំមិនសូវច្បាស់ដែលកាលនោះ តាហ៊ាន តា ប៉ូល ខាងកងទ័ព កងពល តា ប៉ូល ហ្នឹងឯងកាន់កងទ័ពកាលនោះ ។

ដានីៈ តា ប៉ូល កាន់កងទ័ព ចឹងខ្ញុំឮឈ្មោះ តា សុទ្ធ នោះ?

ឡុតៈ មាន តា សុទ្ធ, តា សេង ,តា សុទ្ធ តាហាន ខ្ញុំមិនសូវចាំដែលវាភ្លេចអស់ទៅវាច្រើនឆ្នាំហើយ ។

ដានីៈ ចឹងពូនៅកងទ័ពឈរជើងពីបារាយណ៍មកកំពង់ធំហ្នឹង ឈរជើងនៅហ្នឹងយើងវាយជាមួយតាហាន លន់ នល់?

ឡុតៈ បាទ ។

ដានីៈ ចឹងកាលហ្នឹងលោកពូវាយជាមួយតាហាន លន់ នល់ បានប៉ុន្មានដងដែលតាំងពីចូលមក?

ឡុតៈ ដើរវាយច្រើនហ្នឹងឯង មិនបានគិតរាប់ចំណាំទេ ទៅគ្រប់តែសមរភូមិមានវាយតែខាងមុខនោះអី ដូចថាគេវាយខាងកើតសៀមរាបគេដកតាមវរៈយើងមករួមគ្នាវាយមានអ្នកចាំកន្លែងមានអ្នកវាយដូចគ្នា ។

ដានី: ចឹងកាលឆ្នាំ៧៣ កាលសម្តេចយាងមកភ្នំគូលែន មកលេងនៅអង្គរវត្តកាលហ្នឹង ពូមានទាន់ដែលកាលហ្នឹង?

ឡុត: ទាន់តែពួកខ្ញុំអត់បានទៅ ។

ដានី: កាលទាហានខាងខ្មែរក្រហមខាងអង្គរធំអីហ្នឹង ខ្មែរក្រហមគ្រប់គ្រង?

ឡុត: ខ្មែរក្រហមគ្រប់គ្រងទាំងអស ។

ដានី: ខាង លន់ នល់ នៅតែក្នុងក្រុងទេ?

ឡុត: បាទ ។

ដានី: តែលោកពូអត់មានបានទៅចូលរួមវាយទេកាលហ្នឹង?

ឡុត: អត់ទេ ខ្ញុំនៅចាំសមរភូមិ ។

ដានី: លោកពូនៅហ្នឹងរហូតដល់ពេលណា នៅកន្លែងពីបារាយណ៍ទៅស្រីស្នំ?

ឡុត: នៅរហូតតាំងពី៧៣ដល់៧៥ នេះ ។

ដាន់: រហូតដល់៧៥ តែម្តង?

ឡុត: បាទ! នៅពេលចប់សង្គ្រាមបានបញ្ជូនមកខាងភ្នំដងរែកនេះរហូត ។

ដានី: ចឹងពី៧៣ដល់៧៥ ចឹងលោកអត់មានបានដកទៅវាយខាងភ្នំពេញអត់ទេ?

ឡុត: អត់ ។

ដានី: ចឹងនៅហ្នឹងរហូតពី៧៣ដល់៧៥ ហើយក្តាប់រួមឈ្មោះ តា លន់?

ឡុត: តា លន់ នោះគាត់ទទួលរួមមួយភូមិភាគមិនដឹងកាលនោះខ្ញុំសង្ស័យថាភូមិភាគ តា លន់ តា ពក យើងនេះកាលនោះ ។

ដានី: តា ពក កែ ពក?

ឡុត: បាទ! កែ ពក ។

ដានី: ចឹងលោកពូដល់បែកឆ្នាំ៧៥ ?

ឡុត: បែកឆ្នាំ៧៥ ខ្ញុំគេបញ្ជូនមកភ្នំដងរែកហ្នឹងហើយ មកព្រំដែនហ្នឹង ។

ដានី: បញ្ជូនមកភ្នំដងរែកនៅកន្លែងណាទៅ?

ឡុត: ខ្ញុំនៅខាងមុនស្រុកបន្ទាយអំពិលកាលនោះ មុខប្រាសាទ តា មាន់ រាល់ថ្ងៃនេះ ។

ដានី: នៅមុខប្រាសាទតាមាន់?

ឡុត: បាទ ។

ដានី: នៅក្នុងស្រុកបន្ទាយអំពិលកាលហ្នឹង?

ឡុត: ស្រុកបន្ទាយអំពិល ។

ដានី: កាលហ្នឹងពេលដែលបែកឆ្នាំ៧៥ ហើយ គេបញ្ជូនមកភ្នំដងរែកមុខប្រាសាទតា មាន់ កន្លែងបន្ទាយអំពិលហ្នឹងកាលហ្នឹង លោកពូនៅក្នុងកងពលអីទៅ?

ឡុត: នៅកងពល កាលនោះវាអត់ចាំលេខកងពលកាលនោះដែរ ដឹងថាវាវរសេនាតូច៩០៥ ដដែល វរសេនាធំប៉ុន្មានទេ កាលនោះ ។

ដានី: ពីណាគេប្រធានវរសេនាធំ?

ឡុត: ប្រធានវរសេនាធំឈ្មោះ តា លីម ។

ដានី: ចឹងកងពល?

ឡុត: កងពល មាន តា ប៉ូល, តា ហ៊ាន អីកាលនោះ ។

ដានី: ចឹង តា ប៉ូល, តា ហ៊ាន ?

ឡុត: បាទ! ខ្ញុំចាំអត់ច្បាស់ដែលកាលនោះ ខ្ញុំមិនសូវចាំរឿងលេខកងពល ។

ដានី: លោកពូនៅក្នុងកងទ័ពរបស់តំបន់?

ឡុត: បាទ ។

ដានី: ចឹងតំបន់កាលឆ្នាំ៧៥ ហ្នឹងគេមានដូរឈ្មោះដែលអត់?

ឡុត: អត់ទេ តំបន់៣៥ដដែល ។

ដានី: អត់មានដូរឈ្មោះទៅតំបន់១០៦អីទេ?

ឡុត: អត់ទេ អត់មានដូរទេ ។

ដានី: ចឹងលោកពូមកឈរជើងនៅតំបន់ភ្នំដងរែកតំបន់ប្រាសាទតាមាន់ហ្នឹងដើម្បីអី?

ឡុត: កាលនោះនៅការពារព្រំដែន ។

ដានី: ការពារព្រដែននៅហ្នឹង?

ឡុត: បាទ! និយាយរួមពី៧៥មកទល់៧៨ ដូរចល័តគ្នាចាប់ពីទន្សាយរះទៅដល់រំដួលព្រំប្រទល់ខាងបាត់ដំបងខាងតំបន់៥ កាលនោះយើងមិនទាន់មានខេត្តបន្ទាយមានជ័យណា ។

ដានី: យើងមកទល់ជាមួយទន្សាយរះនៅខាងណា?

ឡុត: ទន្សាយរះនៅខាងជើងសំរោងចំ ។

ដានី: ពីសំរោងទៅដល់ណា?

ឡុត: ទៅដល់ស្រុកបន្ទាយអំពិលព្រំប្រទល់ខេត្តបាត់ដំបង ។

ដានី: ចឹងខាងបន្ទាយអំពិលចាប់ដៃជាមួយកងទ័ពខាងណា?

ឡុត: ខាងបាត់ដំបង ។

ដានី: កងពលពីណាគេខាងបាត់ដំបង?

ឡុត: កងពលពីណាគេកាលនោះ ។

ដានី: កាលហ្នឹងមានស្គាល់ តា ភាព, ទេ សុខ ភាព?

ឡុត: អត់ទេ ។

ដានី: គាត់ឈរជើងនៅជួរខាងពីហ្នឹងរហូតទៅដល់ខាងម៉ាឡៃ?

ឡុត: ខ្ញុំមិនស្គាល់ទេ កាលនោះគេហៅពួកតំបន់៥ ព្រោះបាត់ដំបងកាលនោះគេតំបន់៥ ប្រធានកងពលគេអត់ស្គាល់ទេ ។

ដានី: ឈរម៉ាជួរហ្នឹងរហូតចឹង?

ឡុត: បាទ ។

ដានី: ចឹងផ្លាស់ប្តូរៗ?

ឡុត: បាទ! ផ្លាស់ប្តូរ ។

ដានី: តាំងពី៧៥ដល់៧៨អត់មានផ្លាស់ទៅណាទេ?

ឡុត: អត់ទេ ។

ដានី: នៅតាមព្រំដែនធ្លាប់វាយជាមួយថៃដែលអត់កាលហ្នឹង?

ឡុត: ខ្ញុំបានទៅវាយជាមួយគេបានពីរដងដែរ ។

ដានី: វាយពីរដងវាយនៅណាទៅ?

ឡុត: វាយនៅមុខប្រាសាទតាមាន់នេះម្តង ហើយនៅខាងមុខស្រុកបន្ទាយអំពិលម្តង ។

ដានី: វាយឆ្នាំណា?

ឡុត: វាយឆ្នាំ៧៧ ។

ដានី: ឆ្នាំ៧៧?

ឡុត: ឆ្នាំ៧៧-៧៨នេះឯង ។

ដានី: វាយជាមួយថៃ?

ឡុត: បាទ ។

ដានី: ចឹងកាលហ្នឹង យើងមានឈ្លោះជាមួយថៃដែលចឹង?

ឡុត: យើងវាយឆ្នក់ម្តងៗ ។

ដានី: គេចូលដីយើងយ៉ាងម៉េចបានជាវាយគ្នា?

ឡុត: គេចូលដីយើង យើងចូលដីគេ ។

ដានី: យើងចូលដីគេ គេវាយយើង?

ឡុត: បាទ ។

ដានី៖ ដល់ពេលគេចូលដីយើង យើងវាយគេវិញ?

ឡុត៖ បាទ! ចូលទៅវាយក្នុងភូមិគេហ្នឹងចូលទៅវាយពីរដង ។

ដានី៖ ចូលទៅវាយក្នុងភូមិគេដែរ?

ឡុត៖ បាទ ។

ដានី៖ ចឹងយើងយ៉ាងម៉េចមានដែនការណ៍បានជាចូលទៅវាយក្នុងភូមិគេ?

ឡុត៖ កាលនោះវាមិនរឿងដែនការខាងលើគេដែរ យើងនៅក្រោមបញ្ជាគេដែរ ។

ដានី៖ ចឹងនៅខាងព្រំដែនជាមួយ តា ហ៊ាន, តា ប៉ូល ហ្នឹងគាត់នៅរហូតដល់បែក៧៩ដល់ពេលយួនចូល ឬមួយមានការផ្លាស់ប្តូរ?

ឡុត៖ អត់ទេ! មានការផ្លាសប្តូរចេញឆ្នាំ៧៧ពួកហ្នឹងគេចាប់អស់ហើយ ។

ដានី៖ ចឹង៧៧គេចាប់អស់?

ឡុត៖ ពួក តា ប៉ូល, តា ហ៊ាន គេចាប់អស់ហើយ គេយកខាងភូមិភាគនីរតីខាងតាកែវខាងកំពតមកក្តាប់?

ដានី៖ ពួកនីរតីគេមកក្តាប់វិញ?

ឡុត៖ ដល់ពេលពួកនីរតីមកក្តាប់ ។

ដានី៖ ពេលពួកនីរតីមកក្តាប់ពូមានចាំកងពលអីដែលអត់?

ឡុត៖ អត់មានចាំលេខទេ មានចាំតែឈ្មោះ តា សឿន គាត់ជាប្រធានកងពល ។

ដានី៖ តា សឿន ជាប្រធានកងពល?

ឡុត៖ បាទ ។

ដានី៖ កងពល៧៧៥ត្រូវទេ?

ឡុត៖ មិនទេ មិនដឹងជាកងពលប៉ុន្មានទេ ខ្ញុំភ្លេចហើយ ៧៧៥មានកងពលថ្មីនេះទេ បែប៧៧៥ហ្នឹងដឹង ។

ដានី៖ ដែលគាត់ឈរជើងតាំងពីប្រាសាទព្រះវិហាររហូរហែរមករហូតដល់សំរោង?

ឡុត៖ បាទ! នោះឯង ។

ដានី៖ ចឹងប្រាសាទព្រះវិហារក៏កងពល តា សឿន ឈរជើងដែរ?

ឡុត៖ បាទ! តា សឿន គ្រប់គ្រងទាំងអស់ ។

ដានី៖ ចឹងកាលពូមុន តា ហ៊ាន, តា ប៉ូល ហ្នឹងគាត់មានមួយវរសេនាតូចនៅលើប្រាសាទចឹងទៅគេចិញ្ចឹមជ្រូកចិញ្ចឹមអីនៅកន្លែងជាំក្សាន្តហើយតមកតាមព្រំដែនកាត់តាមអន្លង់វែងរហូតទៅដល់សំរោង ហើយកាលហ្នឹងពូឈរនៅកន្លែងណា?

ឡុតៈ	កាលហ្នឹងខ្ញុំឈរនៅតែខាងមុខសញ្ញាខាងហ្នឹងទេ ឈរនៅមុខសញ្ញាខាងស្រុកបន្ទាយអំពិល ។

ដានីៈ	ចឹងតា ភា ប្រធានវរសេនាតូច៩០៥ គេចាប់ដែរ?

ឡុតៈ	ចាប់ ។

ដានីៈ	ពេលចាប់ទៅដាក់ពីណាជំនួស?

ឡុតៈ	កាលនោះ តា អៀម ជំនួស ។

ដានីៈ	តា អៀម ហ្នឹងនៅណារាល់ថ្ងៃ?

ឡុតៈ	តា អៀមនៅកុងប៊ិនហ្នឹង នៅលំទងថ្មី ។

ដានីៈ	តា អៀម ប្រធានអនុសេនាតូច?

ឡុតៈ	តា អៀម ដូចជាអនុដូចវរងទេ ។

ដានីៈ	ចឹងតា សឿន គាត់នៅណា?

ឡុតៈ	តា សឿន នៅណាទេរាល់ថ្ងៃហ្នឹងអត់ដឹងទេ ។

ដានីៈ	តែគាត់នៅរស់ទេ?

ឡុតៈ	មិនដឹង ព្រោះគាតរត់ចេញពីខ្មែរក្រហមតាំងពីឆ្នាំ៨២-៨៣ ។

ដានីៈ	យ៉ាងម៉េចបានជាគាត់រត់ចេញចឹង?

ឡុតៈ	មិនដឹងជាយ៉ាងម៉េចដែរ ប្រហែលជាមានបញ្ហាច្រើន ។

ដានីៈ	គាត់មានទំនាស់ផ្ទៃក្នុងខាងលើ?

ឡុតៈ	ផ្ទៃក្នុងខាងលើក៏មានខ្លះ ខាងក្រោមដល់យួនចូលស្រុកហ្នឹង សង្គ្រាមហ្នឹងគាត់នៅមាន សម្លាប់ទ័ពទៀត បែងចែកព្រឹត្តិការណ៍បណោយ ។

ដានីៈ	ចឹង តា សឿន ហ្នឹងគាត់កាចដែរ?

ឡុតៈ	គាត់កាច ។

ដានីៈ	គាត់សម្លាប់គេច្រើនដែរ?

ឡុតៈ	បាទ! គាត់ប្រកាន់បក្សពួកខុត្តរនីរតីខ្លាំងពេក ។

ដានីៈ	គាត់នៅតែប្រកាន់ចឹងទៀត?

ឡុតៈ	បាទ ។

ដានីៈ	ចឹងលោកពូជាអ្នកខុត្តរចឹងខាងនីរតីមកកាន់គេមានធ្វើអីលោកពូដែរ?

ឡុតៈ	ទេ ខ្ញុំអត់មានអីទេ ។

ដានីៈ	យើងកូនទាហានអត់អីទេ?

ឡុតៈ	បាទ ។

ដានី៖ ចឹងកាលហ្នឹងពូមានតួនាទីអត់?

ឡុត៖ តួនាទីកាលនោះត្រឹមកងតូចដែលហ្នឹង តែពួកនិរតីចុះមកខ្ញុំត្រូវគេដកតួនាទីអស់នៅជាមហាជនធម្មតា ។

ដានី៖ គេដកតួនាទីឲ្យទៅជាមហាជន?

ឡុត៖ បាទ ។

ដានី៖ ពូមានអន់ចិត្តមានតូចចិត្តដែលអត់?

ឡុត៖ កាលហ្នឹងអត់មានគិតរឿងអន់ចិត្តតូចចិត្ត ដោយថាយើងចាញ់ផ្នែកនយោបាយគេដងឲ្យតែបានរស់ ។

ដានី៖ ចាញ់ផ្នែកនយោបាយខាងនិរតី?

ឡុត៖ បាទ ។

ដានី៖ កាលហ្នឹងពួកនិរតីខ្លាំងៗ ឬមួយយ៉ាងម៉េច?

ឡុត៖ ខ្លាំងគួរសមដែរហ្នឹង ។

ដានី៖ គេពូកែដាង?

ឡុត៖ ទេ រឿងការវាយដូចជាមិនពូកែដាងទេ ទេដូចជាគេចោទគ្នាទៅវិញទៅមកមិនដឹងជាខាងណាក្បត់ខាងណា ឆ្នាំ៧៦-៧៧មកផ្លាស់ពួកនិរតីមកចាប់ពួកខត្តរ ថាអ្នកខត្តរក្បត់ដល់ពេលគេយកពីនិរតីខាងព្រះវិហារមកក្តាប់ ដល់ឆ្នាំ៧៨ចាប់និរតីទៀត យកពាកបស្ចឹមមកក្តាប់ពីលើទៀត ពីលើនិរតីមួយជាន់ទៀត វាច្របូលច្របល់ច្រើន តែពេលសព្វថ្ងៃវិភាគទៅមួយជំនាន់នោះ ថាឲ្យពីណាក្បត់ក៏វាមិនច្បាស់ តែពួកវាដូចជាដណ្តើមអំណាចគ្នានិយមទៅតាមភូមិភាគ ។

ដានី៖ ចឹង?

ឡុត៖ បាទ! នេះគ្រាន់តែជាការវិភាគរបស់ខ្ញុំទេ ការស្មានរបស់ខ្ញុំ ។

ដានី៖ ចឹងតា សុទ្ធអីនោះ ។

ឡុត៖ តា សុទ្ធ ចាប់អស់មួយជំនាន់ហ្នឹង ។

ដានី៖ ចាប់អស់ហើយដាក់ណាមកជំនួសវិញ?

ឡុត៖ ដាក់ពួកនិរតីមក ។

ដានី៖ ឈ្មោះ អី?

ឡុត៖ ឈ្មោះ សែ ។

ដានី៖ ចឹងមាន តា សែ ហ្នឹងពីណាទៀតដែលមកជំនួស?

ឡុតៈ ខ្ញុំស្គាល់មិនអស់ដែរ ដឹងថា សៀមរាបនោះ តា សែ មកដល់ខត្តរមានជ័យ តា សឿន ។

ដានីៈ នៅសៀមរាប តា សែ នៅខត្តរមានជ័យ តា សឿន?

ឡុតៈ បាទ ។

ដានីៈ ចឹងគាត់ក្តាប់ទ័ពផងក្តាប់ប្រជាជនផង?

ឡុតៈ បាទ ។

ដានីៈ ចឹងតា សែ តា សឿន ហ្នឹងពួកនិរតីមក?

ឡុតៈ បាទ ។

ដានីៈ ចឹងពួកបស្ចឹម?

ឡុតៈ បស្ចឹមកងពលឈ្មោះ តា យន ។

ដានីៈ តា យន មកជំនួសពីណា?

ឡុតៈ តា យន មកជំនួសពីទេ ។

ដានីៈ ចឹង តា សឿន, តា សែ គេចាប់ទៀត?

ឡុតៈ អត់ចាប់ទេ កាលនោះ គេគ្រាន់មកគ្រប់គ្រងពីលើនោះទៀត លើ តា សឿនទៀត ។

ដានីៈ តា យន មកជំនួស តា សឿន?

ឡុតៈ បាទ ។

ដានីៈ ចឹងជំនួសតា សែ ពីណាគេ?

ឡុតៈ តា សែ អត់ដឹងដែលកាលនោះ ។

ដានីៈ ចឹងមានដែលឮឈ្មោះ តា សឿង?

ឡុតៈ អ៊ំ! តា សឿង នោះឯងជំនួស តា សែ នោះ ។

ដានីៈ ចឹងខាងកងទ័ពដូចជាលោកពូត្រឹមកងតូចចឹងគេអត់មានធ្វើអីទេ គ្រាន់តែទម្លាក់ទូនាទីឲ្យទៅជាមហាជន?

ឡុតៈ បាទ ។

ដានីៈ គេមានរករឿងគេមានធ្វើទារុណកម្មលត់ដុយើងដែលអត់?

ឡុតៈ ទេ! ខ្ញុំអត់មានបានលត់ដុំអីហ្នឹងគេទេ ខ្លះគេយកទៅលត់ដុំយកទៅធ្វើបាបនោះអ្នកដែលចូល បក្សចូលសម្ព័ន្ធគេ តែមានយុទ្ធជនខ្លះមានគេចាប់យកទៅខ្លះដែរ ។

ដានីៈ ចឹងមានយុទ្ធជនខ្លះគេចាប់ដែរ?

ឡុតៈ បាទ! ដូចជាយើងនិយាយពាក្យសម្តីឆ្គង ។

ដានី៖ ចឹងកាលហ្នឹងគេចាប់ចុះចាប់ឡើងចឹងពូមានដែលឃើញគេចាប់ផ្ទាល់ភ្នែកពេលយកទៅណា មានដែលឃើញដែរ?

ឡុត៖ អត់ទេ កាលនោះគេត្រូវការចាប់គេហៅមករៀន រៀនហើយបាត់ខ្លួន ។

ដានី៖ រៀនហើយបាត់ខ្លួន?

ឡុត៖ បាត់ខ្លួនហើយដឹងថាគេចាប់ទៅហើយ ។

ដានី៖ ចឹងអានេះពូដឹងពីណាដែលទៅរៀនហើយបាត់ខ្លួនហ្នឹង ដឹងថាគេចាប់?

ឡុត៖ ទេ ដល់ពេលគេចាប់ហ៎យទៅបានគេទៅប្រកាសប្រាប់យើងនោះ ថាអាហ្នឹងវាក្បត់ចេះ ក្បត់ចុះហ្នឹងណាស់ ។

ដានី៖ ចឹងកាលគេចាប់ តា ហ៊ាន, តា មូល, តា ប៊ូល អីហ្នឹងកាលហ្នឹងទៅប្រកាសប្រាប់កងទ័ពដែរ កាលហ្នឹង?

ឡុត៖ បាទ ។

ដានី៖ គេប្រកាសថាយ៉ាងម៉េច?

ឡុត៖ គេប្រកាសថាពួកហ្នឹងក្បត់ ។

ដានី៖ ក្បត់យ៉ាងម៉េចក្បត់ហ្នឹង?

ឡុត៖ មិនដឹងជាក្បត់យ៉ាងម៉េច ក្បត់ពីបក្សក្បត់ពីនេះគេ ។

ដានី៖ ចឹងប្រកាសថា ពួកហ្នឹងក្បត់ដឹងថាគេចាប់ហើយ?

ឡុត៖ បាទ ។

ដានី៖ ដឹងថាពួកហ្នឹងស្លាប់អស់ហើយ?

ឡុត៖ ដឹងថាស្លាប់ ព្រោះមនុស្សដឹងថាគេចាប់ហើយ កាលនោះគេចោទខ្មែរអាមេរិច ។

ដានី៖ ចោទខ្មែរអាមេរិច?

ឡុត៖ បាទ ។

ដានី៖ ចុះពេលគេធ្វើទារុណកម្ម ឬកគេធ្វើសម្លាប់ដាក់គុកនៅក្បែរកន្លែងលោកពូហ្នឹងមានដែរ អត់?

ឡុត៖ អត់មានទេ ។

ដានី៖ ចឹងដូចជាកងទ័ពខុសវិន័យអីគេចាប់គេមាន?

ឡុត៖ អត់មានទេ បើគេចាប់បញ្ជូនមកខាងសំរោង បញ្ជូនមកកន្លែងកងពលសំរោង ។

ដានី៖ ចឹងនៅសំរោងមានកន្លែងគុកគេដែរ?

ឡុត៖ មាន ។

ដានី៖ គុកនៅម្តុំណា?

ឡុត៖ គុកកាលនោះនៅត្រង់ណាទេ នៅនិមិត្តបឹងស្នោនេះ ។

ដានី៖ គុកហ្នឹងកងទ័ពជាអ្នកក្តាប់ដែលមិនមែនទេ?

ឡុត៖ ទេ ខាងប្រធានគុកគេដោយឡែកផ្សេង ។

ដានី៖ ពីណាគេប្រធានគុកកាលហ្នឹង?

ឡុត៖ ប្រធានគុកឈ្មោះ តា ម៉ុល ។

ដានី៖ តា ម៉ុល ឥឡូវគាត់នៅណា?

ឡុត៖ អត់ដឹងដែរ តា ម៉ុល ដល់គេចាប់តា ម៉ុល មួយសានោះទៅពីណាក្រោយទៀតអត់ស្គាល់ដែរ ជិនាន់នីរតីដឹងពីណា សម័យកាលនោះយើងអត់ហ៊ានស៊ើបសួរស្រាវជ្រាវគេដែរ ។

ដានី៖ តែគេចាប់ហើយយើងអត់ហ៊ានសួរនាំអីទេ?

ឡុត៖ បាទ ។

ដានី៖ ចឹងកាលហ្នឹងយើងភ័យខ្លាចដែលអត់ដូចជាលោកពូជាកងទ័ពអី ខ្លាចគេចាប់ ឬមួយយ៉ាងម៉េចអី?

ឡុត៖ មានការភ័យដែលតើ ភ័យយ៉ាងម៉េចភ័យខ្លាចគេចាប់គេសម្លាប់ចឹងដែរ ព្រោះមើលឃើញបាត់អស់ច្រើនហើយ ។

ដានី៖ តែបើឲ្យឃើញផ្ទាល់ភ្នែកមិនដែលឃើញទេ?

ឡុត៖ មិនដែលឃើញទេ ។

ដានី៖ ដូចជានីរតីមកចាប់ខាងខត្តរចាប់ឆ្នាំ៧៧?

ឡុត៖ ៧៧ ។

ដានី៖ ៧៧ចឹងខាងបស្ចិមមកចាប់ខាងនីរតីវិញ?

ឡុត៖ ៧៨ហ្នឹង ដល់៧៩យួនចូលស្រុក ។

ដានី៖ ចឹងពេលចាប់បញ្ជូនមកណាទៅណាទៅ?

ឡុត៖ ទេ មិនដឹងជាបញ្ជូនទៅណាមកណីទេ ខ្ញុំមិនដឹងរឿងទេ គេឲ្យធ្វើអីយើងធ្វើតែនោះ ។

ដានី៖ ចឹងកាលលោកពូនៅកងទ័ពចឹងយើងធ្លាប់បានទៅលេងផ្ទះទេ?

ឡុត៖ អត់ទេ សម័យអត់ទេ ។

ដានី៖ លោកពូមិនចង់ទៅ ឬមួយគេមិនឲ្យ?

ឡុត៖ គេមិនមក ។

ដានី៖ គេថាយ៉ាងម៉េច?

ឡុតៈ សុំច្បាប់គេ គេថាឈប់សិនៗ ។

ដានីៈ ពីណាគេថា ឈប់សិនហ្នឹង?

ឡុតៈ មេៗប្រធានវរៈប្រធានអីហ្នឹង គេសន្យាថាខែនេះខែនោះ ។

ដានីៈ ពូកាលហ្នឹងនៅខត្តរប្រធានវរសេនាធំឈ្មោះ តា លីម ។

ឡុតៈ បាទ ។

ដានីៈ ដល់ពេលពួកនីរតីមកឈ្មោះ តាអីវិញ?

ឡុតៈ ឈ្មោះ តា គេម ។

ដានីៈ តា គេម ប្រធានវរសេនាធំ តា សឿន ប្រធានកងពល?

ឡុតៈ បាទ ។

ដានីៈ ពេល តា យន មកគាត់ធ្វើប្រធានកងពលជំនួស តា សឿន វិញ?

ឡុតៈ កាលហ្នឹង ដឹងតា សឿន ឬពីណាទេ តា សឿន ដកហើយកាលនោះ ។

ដានីៈ ដកទៅណាវិញ?

ឡុតៈ មិនដឹងជាដកទៅណាកាលនោះ ដល់បានឃួនចូលមកបាន តា សឿន មកវិញ ពួក តា គេម វាយពួក តា យន ចឹងទៅ ។

ដានីៈ តា យន តា គេម វាយទៀត?

ឡុតៈ បាទ ។

ដានីៈ ចឹងតា យន ស្លាប់ទៀតចឹង?

ឡុតៈ ទេ តា យន ហ្នឹងមិនដឹងជាស្លាប់ ឬរស់ មានស្លាប់មួយមិនដឹងថា ស្លាប់ តា យន ដឹងថា ស្លាប់ តា សឿង ព្រោះតា យន ដូចជាមិនស្លាប់ទេ ។

ដានីៈ ចឹងស្លាប់ពីណា?

ឡុតៈ ស្លាប់ តា សឿង មិនដឹង ។

ដានីៈ ចឹង តា សឿង ស្លាប់ពេល៧៩ហ្នឹង?

ឡុតៈ បាទ ។

ដានីៈ ស្លាប់ហ្នឹងដោយសារ តា គេម វាយទេ?

ឡុតៈ ស្លាប់ដោយសារខ្មែរក្រហមគ្នាឯងវាយ ។

ដានីៈ ចុះម៉េចបានចឹង?

ឡុតៈ ចុះមួយរកវាយមួយដែរ ។

ដានីៈ វាយទៅវាយមក?

ឡុត៖ បាទ ។

ដានី៖ ចឹងយ៉ាងម៉េចចឹងនៅជាមួយគ្នាច្រើនតែរកសម្លាប់គ្នា?

ឡុត៖ ចឹងបានជាខ្ញុំថា ដូចខ្ញុំគិតចឹង អ្នកណាក្បត់ដូចជាមិនមានអ្នកណាក្បត់ពីណាទេ មានតែ
ជណ្តើមអណាចគ្នា តាមខ្សែគេ ចង់យកខ្សែគេមកដាក់ ។

ដានី៖ ចឹងខ្សែលោកពូខាងខត្តរគេសម្លាប់មេៗអស់លោកពូទៅជាយ៉ាងម៉េចទៅ?

ឡុត៖ កាលនោះនៅមានការព្រួយបារម្ភណ៍ដូចខ្ញុំថាចេះឯង ។

ដានី៖ យើងអស់មេអស់កើយយើងលែងបានឡើងបុណ្យសក្តិអីទៀត?

ឡុត៖ បាទ! បុណ្យសក្តិខាងខត្តរបានឡើងនៅពេលយួនចូលស្រុកវិញតើ៧៩នេះទៅមានពួកខត្តរ
ឡើងធ្វើមេវិញ ។

ដានី៖ ចឹងលោកពូនៅកងទ័ពហ្នឹងរហូតដល់យួនចូលមក?

ឡុត៖ បាទ ។

ដានី៖ នៅទល់មុខប្រាសាទតាមាន់រហូត?

ឡុត៖ បាទ! នៅចាប់ពីទន្សាយរះទៅ ។

ដានី៖ ចឹងកាលហ្នឹងកងទ័ពអីយើងមានហូបចុកគ្រប់គ្រាន់ទេ?

ឡុត៖ កងទ័ពនៅជួរមុខដូចខ្ញុំបានគ្រប់គ្រាន់ដែរ តែបើអ្នកនៅខាងក្រោយហូបបបរទេ ។

ដានី៖ ចឹងកាលហ្នឹងមានអ្នកនៅខាងមុខនៅខាងក្រោយដែរ?

ឡុត៖ បាទ! អ្នកនៅតាមជើងភ្នំហ្នឹងអ្នកនៅតាមក្រោយដែរ ដូចជានៅអ្នកនៅអន្លង់វែងចេះមាន
អ្នកភូមិអន្លង់វែងចេះមានអ្នកនៅតាមជើងភ្នំចេះ ។

ដានី៖ ចឹងគ្រួសារ ឬមួយកងទ័ព?

ឡុត៖ គ្រួសារកងទ័ពក៏នៅ ។

ដានី៖ តែលោកពូនៅតែសមរភូមិមុខរហូត?

ឡុត៖ បាទ ។

ដានី៖ នៅមុខយើងអត់មានធ្វើអីទេ នៅការពារហូបចុកទេ?

ឡុត៖ បាទ! ដាក់មីនដាក់អីការពារ ។

ដានី៖ អត់មានធ្វើស្រែចម្ការអីទេ?

ឡុត៖ ចម្ការធ្វើខ្លះដែលដាំដុំវិញហ្នឹងបន្តិចបន្តួច តែវាមិនបាកដូចគ្នាអ្នកនៅក្រោយ ។

ដានី៖ តែយើងបានហូបបាយ?

ឡុត៖ បាទ ។

ដានី៖ ម្ហូបអាហារអី?

ឡុត៖ ម្ហូបអាហារអីយើងរកខ្លួនយើង តាមជើងភ្នំពីដើមសប្បុរសត្វ ខែនេះត្រកួតពេញហ្នឹង ត្រកួត អណ្តើកសប្បុរណាស់ ដឹកយកមកឲ្យអ្នកខាងក្រោយ ។

ដានី៖ ត្រកួតហ្នឹង នៅក្នុងហ្នឹងឃើញវា វាៗតែម្តង?

ឡុត៖ បាទ! ផ្តៃ ។

ដានី៖ យើងមានផ្តៃដែរ?

ឡុត៖ បាទ ។

ដានី៖ ត្រកួតដូចសត្វក្រពើហ្នឹង?

ឡុត៖ បាទ ។

ដានី៖ អាហ្នឹងយើងហូបដែលឆ្ងាញ់ទេ?

ឡុត៖ មានអីឆ្ងាញ់ អ្នកនៅមុខកាលនោះមិនខ្វះទេ តែត្រីយើងរកបានភាគតិចដែរ វាសប្បុរតែសត្វ ។

ដានី៖ មានសត្វត្រកួតមានសត្វអីទៀត?

ឡុត៖ មានត្រកួត អណ្តើក សំពោជ ឈ្លូស ជ្រូកព្រៃ ជួនកាលទៅវាជាន់មីនផាប់ ។

ដានី៖ វាជាន់មីន បើអត់នេះទេ យើងទៅចាប់យ៉ាងម៉េចទៅការពារព្រំដែនហ្នឹង?

ឡុត៖ មានចាប់យ៉ាងម៉េចទេ យើងដើរធ្វើការចំវាបាញ់ទៅ ទាំងទន្សោងអីក៏មាន ។

ដានី៖ ទន្សោងៗធំៗដូចគោហ្នឹង?

ឡុត៖ បាទ ។

ដានី៖ អាហ្នឹងយើងបាញ់ដែរ?

ឡុត៖ បាញ់ដែលកាលនោះ ឲ្យតែចំ ។

ដានី៖ បាញ់យកធ្វើងៀត?

ឡុត៖ យកធ្វើងៀត យកមកឲ្យគេក្រោយ ខ្ញុំនៅខាងក្រោយជាមួយគេបានប៉ុន្មានខែដែរ នៅចំខែប្រាំងបានហូបបាយ ។

ដានី៖ នៅក្រោយកន្លែងណា?

ឡុត៖ កាលនោះខ្ញុំនៅភូមិថ្នល់ ។

ដានី៖ ភូមិថ្នល់ក្នុង?

ឡុត៖ ភូមិថ្នល់ក្នុងស្រុកបន្ទាយអំពិល ។

ដានី៖ កាលហ្នឹងគណៈស្រុកបន្ទាយអំពិលឈ្មោះអី?

ឡុត: ឈ្មោះអីទេ អត់ចាំផង ភ្លេចបាត់ហើយ ។

ដានី: ចឹងលោកពូចេញពីកងទ័ពតាំងពីឆ្នាំ៧៣អត់ដែលទៅលេងផ្ទះអត់ដែលបានជំណើងអ្នកផ្ទះទេចឹង?

ឡុត: អត់ចាប់ពី៧៥មកអត់ដែលបានទៅលេងផ្ទះ ៧៣-៧៤ ត្រឹមស្រុកចប់ លន់ នល់ មកគេបញ្ជូនមកភ្នំដងរែកនេះ ។

ដានី: បានទៅលេងផ្ទះដែរ?

ឡុត: អត់មានបានទៅទេ កាលនៅសង្គ្រាមវាយជាមួយ លន់ នល់ បានទៅញឹកដែរ ត្រូវការឆ្លងកាត់ជួរពីសមរភូមិមួយទៅសមរភូមិមួយត្រូវការឆ្លងកាត់ភូមិត្រូវការឆ្លងកាត់ភូមិបានចូលលេង ។

ដានី: ចឹងទោះលោកពូនៅតាមភ្នំដងរែក លោកពូថា កាលជំនាន់បីឆ្នាំហ្នឹងមានការចាប់មនុស្សមានការសម្លាប់មនុស្សធ្វើទារុណកម្មដែលចឹង?

ឡុត: បាទ! ថាចឹងទៅចុះព្រោះវាបាត់កងទ័ពបណ្តើរៗ ។

ដានី: តែប្រជាជនមានដឹងដែរអត់?

ឡុត: ប្រជាជនគ្រាន់តែឮៗ ។

ដានី: តែបើចិត្តលោកពូកាលជំនាន់ហ្នឹងមានជឿថា មានការចាប់មនុស្សយកទៅសម្លាប់ ឬធ្វើទារុណកម្មអីដែលអត់?

ឡុត: ជឿ ។

ដានី: បាទ!ព្រោះពូមីងខ្លះទៅតាមព្រំដែនគាត់ គាត់ធ្វើកងទ័ពគាត់ថា គាត់មិនដែលដឹង តែលោកពូជឿ?

ឡុត: ជឿ ព្រោះបានថាជឿ សូម្បីតែទ័ពនៅតែចាប់ ។

ដានី: ចុះលោកពូពេលដែលយួនចូលស្រុកយើងនៅខែមករាឆ្នាំ៧៩ យ៉ាងម៉េចទៅកងទ័ពលោកពូត្រូវរត់ត្រូវភាសខ្លួនទៅណាទៅ?

ឡុត: ភៀសខ្លួននៅតែតាមជើងភ្នំនេះឯង ។

ដានី: នៅជើងភ្នំនៅណា?

ឡុត: នៅផ្នែកខាងលិចហ្នឹង ។

ដានី: គេហៅខាងស្រុកអីគេ?

ឡុត: ខាងស្រុកបន្ទាយអំពិលហ្នឹង ។

ដានីៈ ខាងស្រុកបន្ទាយអំពិលហ្នឹងគេហៅខាងអីគេ ដូចជា១០០១-១០០២-១០០៣-៨០៨ ឬក៏អីគេកន្លែងហ្នឹង?

ឡុតៈ ខាងនោះអត់មានលេខចុះទេ គេហៅមុខថ្នល់ធំ កាលនោះមុខប្រាសាទតាមាន់នេះ មិនបាន ហៅប្រាសាទតាមាន់នេះទេ គេហៅមុខថ្នល់ធំ កាលនោះជំនាន់ លន់ នល់ គេឈូសផ្លូវធំណាស់ ឈូសថ្នល់ឡើងទៅថៃវាធំ ដល់ហើយហៅតែមុខថ្នល់ធំហ្នឹង ។

ដានីៈ ចឹងកាលហ្នឹងពូនៅហ្នឹងយូរទេ កាលយួនចូលហើយ?

ឡុតៈ នៅយូរដែរ ៧៩-៨០ខ្ញុំនៅចាប់ពីសំរោងទៅរហូតទាល់តែដាច់ជើងឆ្នាំ៨១ ។

ដានីៈ ចឹង៨១ពូពិការជើង ចឹង៨១លោកពូនៅខាងហ្នឹងនៅឡើយទេ?

ឡុតៈ បាទ ។

ដានីៈ នៅឆ្នាំ៨០-៨១ ពិការជើងពិការជើងខាងហ្នឹងមកទេ?

ឡុតៈ បាទ! ពិការជើងនៅខាងហ្នឹង ។

ដានីៈ ពិការជើងនៅកន្លែងណា?

ឡុតៈ កាលខ្ញុំត្រូវមីននេះ ខ្ញុំនៅត្រូវជើងខាងជើងទីក្រុងសំរោង ខាងជើងសាលាខេត្តសំរោងរាល់ថ្ងៃ ។

ដានីៈ ខាងជើងសាលាខេត្តសំរោងត្រូវមីនពីខាងណា?

ឡុតៈ ត្រូវមីនរបស់យួន ។

ដានីៈ ចឹងកាលហ្នឹងពូធ្វើអីបានពូត្រូវមីនហ្នឹង?

ឡុតៈ ទៅធ្វើការស៊ើបការ ។

ដានីៈ ចូលទៅស៊ើបការ?

ឡុតៈ បាទ ។

ដានីៈ ចូលស៊ើបការនៅកន្លែងបន្ទាយយួនហ្នឹងឯងស៊ើបការយ៉ាងម៉េច?

ឡុតៈ នៅកន្លែងយួនហ្នឹង ស៊ើបការមកសំរោងហ្នឹងឯង?

ដានីៈ ពេលយប់?

ឡុតៈ ពេលថ្ងៃ ដែលត្រូវនេះត្រូវព្រឹក ។

ដានីៈ មកប៉ុន្មាននាក់?

ឡុតៈ មកគ្នាបីនាក់ ដែលខ្ញុំចូលស៊ើបការហ្នឹងបីនាក់ តែកម្លាំងធំហ្នឹងនៅក្រោយ ។

ដានីៈ ចូលស៊ើបការក្នុងបន្ទាយយួនតែម្តង?

ឡុតៈ បាទ! តែមិនទាន់ដល់បន្ទាយទេ ខ្ញុំត្រូវមីន ។

ដានី៖ តែគំរោងយើងចង់ទៅបន្ទាយយួន?

ឡុត៖ បាទ ។

ដានី៖ យើងលួចចូលទៅ ឬមួយយើងដើរទៅធម្មតា?

ឡុត៖ ដែលត្រូវនេះទើបដើរទេ មិនទាន់បានលូតដល់បន្ទាយយួនទេ ។

ដានី៖ ចឹងកាលហ្នឹងលោកពូមានតួនាទីអីពេលលោកពូកាលហ្នឹង?

ឡុត៖ មានតួនាទីកាន់កងធំ ។

ដានី៖ ជាកងធំ?

ឡុត៖ បាទ! កងធំកងពិសេសប្រចាំវរសេនាធំ ។

ដានី៖ ជាកងពិសេសរបស់កងវរៈសេនាធំណា?

ឡុត៖ វរសេនាធំ៤៣ ។

ដានី៖ កងវរសេនាធំ៤៣របស់ពីណាគេ?

ឡុត៖ កាលហ្នឹង តា អៀម យើងទៅថ្មីនេះកាន់ខាងវរសេនាធំ ។

ដានី៖ តា អៀម គាត់កាន់វរសេនាធំ៤៣របស់កងពលណា?

ឡុត៖ កងពលលេខប៉ុន្មានទេ ភ្លេចបាត់ហើយខ្ញុំនោះ ។

ដានី៖ កងពល តា សឿន នេះ តា សឿន គាត់មកគ្រប់គ្រងវិញ ។

ឡុត៖ តា សឿន មកគ្រប់គ្រងវិញ ចឹង តា យន?

ដានី៖ តា យន ពួកហ្នឹងដេញទៅដល់ភ្នំឆត្រ ។

ឡុត៖ ពួកណាដេញ?

ដានី៖ ពួកនីរតីដេញធ្លាក់ទៅដល់ភ្នំឆត្រវិញ?

ឡុត៖ បាទ! ច្រើនវគ្គច្រើនជាន់ ។

ដានី៖ តា សឿន មកគ្រប់គ្រងវិញ?

ឡុត៖ បាទ ។

ដានី៖ ដល់ពេលចឹងកងធំ ដល់ពូត្រូវពិការជើងហើយលោកពូទៅសម្រាកពេទ្យនៅណាទៅ?

ឡុត៖ ពេទ្យខ្មែរក្រហមហ្នឹង កន្លែងភ្នំដងរែក ។

ដានី៖ ចឹងកាលហ្នឹងយួនអត់មានធ្វើអីទេ ពេលពូផ្ទុះមីនជាន់មីន?

ឡុត៖ វាមកអត់ទាន់ ។

ដានី៖ យើងមានគ្នាសែង?

ឡុត៖ បាទ ។

ដានី៖ សែងមកដេកលើភ្នំដងរែក?

ឡុត៖ បាទ ។

ដានី៖ កន្លែងណា?

ឡុត៖ គេហៅអណ្ដែងមុត ។

ដានី៖ នៅអណ្ដែងមុត?

ឡុត៖ នៅខាងជើងសំរោងចំ ។

ដានី៖ លោកពូនៅសម្រាកពេទ្យអស់រយៈពេលប៉ុន្មានទៅបានជា?

ឡុត៖ ដូចជាបីខែ ។

ដានី៖ បន្ទាប់ពីសម្រាកបីខែហើយលោកពូមកសម្រាកនៅណាវិញទៅ?

ឡុត៖ មកនៅតាមអគ្គភាព ។

ដានី៖ មកនៅតាមអគ្គភាពវិញ?

ឡុត៖ នៅក្នុងអគ្គភាពវរសេនាធំ ។

ដានី៖ មកនៅកន្លែងវរសេនាធំ៨៣ដដែល?

ឡុត៖ បាទ ។

ដានី៖ មកធ្វើអីវិញទៅនៅអគ្គភាពហ្នឹង?

ឡុត៖ មានបានធ្វើអីទេ នៅជួយមើលគ្រាប់រំសេវអី ពេលដែលគេដឹកមកដាក់ហ្នឹង ។

ដានី៖ លោកពូមកគ្រប់គ្រងនៅមន្ទីរវិញ?

ឡុត៖ បាទ ។

ដានី៖ មកគ្រប់គ្រងនៅមន្ទីរវរសេនាធំ៨៣ របស់ តា អៀម ហ្នឹង កាលហ្នឹងលោកពូអត់មានចាំថាកងពលលេខប៉ុន្មាន?

ឡុត៖ អត់ចាំទេ កាលនោះមិនទាន់ដាក់៩១២ទេ នៅប៉ុន្មានដែលលោកគ្រូថាពីមុនហ្នឹង ។

ដានី៖ ៧៧៥?

ឡុត៖ បាទ!បែបនៅកងពលនោះឯង មិនទាន់ដូរទេ ។

ដានី៖ តា សឿន គាត់ធ្វើប្រធាន ពីណាអនុ តា សឿន?

ឡុត៖ ចាំមិនបានទេ កាលនោះ ។

ដានី៖ ចឹងលោកពូមន្ទីរវរសេធំនៅជិតអណ្ដែងមុត?

ឡុត៖ បាទ ។

ដានី៖ នៅដល់ពេលណាទៅនៅកន្លែងនោះហ្នឹង?

ឡុត៖ នៅឡើងឃុំរដែរ ដាក់មួយឆ្នាំគេដកមកនៅ៨០៨ ។

ដានី៖ ឆ្នាំណាដែលដកមក៨០៨?

ឡុត៖ ឆ្នាំ៨២ អាចមកខែ៨-៩ ។

ដានី៖ ចឹងមកនៅ៨០៨វិញ?

ឡុត៖ បាទ ។

ដានី៖ ចឹងកងពលមកទាំងអស់គ្នា ឬមួយមានការបែងចែកអី?

ឡុត៖ មកទាំងអស់ កាលហ្នឹងគេដកមកនៅហ្នឹងទាំងអស់ ។

ដានី៖ ដកមកនៅហ្នឹងទាំងអស់?

ឡុត៖ បាទ ។

ដានី៖ ទាំងវរៈទាំង តា សឿន អីមកទាំងអស់?

ឡុត៖ អត់ទេ តា សឿន គាត់នោះ កាលនោះនៅកាល៨២នោះ កងពល៩១២ហើយ តា ភាព គាត់ឡើងកាន់កងពល ។

ដានី៖ ចឹងខ្មោច តា ភាព ពេលឆ្នាំ៨២ មកនៅ៨០៨នេះកងពលដូរទៅជា៩១២?

ឡុត៖ ទៅជា៩១២ហើយ ។

ដានី៖ ចឹងអតីតកងពល តា សឿន ទាំងអស់ហ្នឹង ដូរឈ្មោះទៅ៩១២វិញ?

ឡុត៖ អត់ទេ កាលនោះគេបំបែកច្រើន កាលនោះ តា សឿន គាត់គ្រប់គ្រងទាំងអស់៩៨០ ៩១២នេះក៏នៅលើគាត់គ្រប់គ្រងទាំងអស់ កងពល៩៨០ កងពល៧៨៥ កងពល៩៩០ កាល ។

ដានី៖ មានប៉ុន្មានទៀត?

ឡុត៖ ៩១២ កាលនោះផ្លាស់មកទាំងអស់៩១២មកទាំងអស់ហ្នឹងឯង ។

ដានី៖ ចឹងកងពល៩១២ភាគច្រើនកងទ័ពបំបែកមកពីខាងណាខ្លះមក៩១២ហ្នឹង?

ឡុត៖ ៩១២នេះនៅប៉ែកខាងលិចសំរោង ម៉ាជីនាន់៧៥ វរសេនាធំ១១មុន ។

ដានី៖ បាទ! វរសេនាធំ តា លីម?

ឡុត៖ ដល់នេះទៅគេរៀបមួយកងពលតែម្តង ពេលដែលយួនចូលមក ។

ដានី៖ វរសេនាធំ តា លីម ហើយមានពីណាទៀត៩១២?

ឡុត៖ ៩១២កាលមុនកវរសេនាធំ តា លីម ហ្នឹងឯង មើលយើងនិយាយមកសម័យ៤៣ កាលនោះវាមានពីរវរសេនាធំ មានវរសេនាធំ៤៣វរសេនាធំ៤៤ ដែលយើងបង្កើត កងពល៩១២ ។

ដានី:	ចឹងមានពីរវរសេនាធំហ្នឹងមាន៤៣-៤៤?

ឡុត:	បាទ ។

ដានី:	ហើយមានថែមវរសេនាធំណាមួយទៀតបានបង្កើតបានបីវរសេនាធំ?

ឡុត:	មិនដឹងជាថែមពីណាកាលហ្នឹង ។

ដានី:	កាលហ្នឹងវរសេនាធំ តា លីម តា អៀម?

ឡុត:	តា អៀម នោះគេចាប់ខ្លួនគាត់ហើយ ។

ដានី:	ចឹងដល់ពេលក្រោយមក៤៣ តា អៀម ។

ឡុត:	តា អៀម ។

ដានី:	ចុះ៤៤?

ឡុត:	៤៤ តារ៉េត ។

ដានី:	តា រ៉េតនៅណាឥឡូវ?

ឡុត:	តា រ៉េត ទៅប៉ារ៉ាំ ស្លាប់ប៉ិចមិនដឹង បាតឈ្មោះ មិនដែលឮ ឮតែឈ្មោះ តា វ៉ាង ។

ដានី:	ចុះ តា អៀម អនុគាត់ឈ្មោះអី៤៣?

ឡុត:	តា អៀម អនុជំនាន់នោះ តា អ៊ិត ។

ដានី:	តា អ៊ិត?

ឡុត:	ដល់ដក តា អ៊ិត មកនេះទៅ តា ហេង ដកតា អ៊ិត មកឡើង តា ហេង តា សឿន វរសេនាធំដូចគ្នា ។

ដានី:	ឡើង តា សឿន?

ឡុត:	តា សឿន ផ្សេងមួយទៀត ។

ដានី:	តា សឿន នៅណា?

ឡុត:	តា សឿន កំបុតជើងនៅអន្លង់វែងរាល់ថ្ងៃ ។

ដានី:	ប្រាក់ សឿន?

ឡុត:	ទេ ។

ដានី:	សឿន ណាចេះ?

ឡុត:	សឿន កំបុតជើង ។

ដានី:	សឿន មានគគោក សឿន ជំទប់ទី១នៅថ្នាតក៏ឈ្មោះ សឿន?

ឡុត:	មិនមែន សឿន នោះទេ ។

ដានី:	តា សឿន ណាទៅ?

ឡុត៖ សឿន សព្វថ្ងៃគាត់នៅអាចារ្យវត្តហើយ ។
ដានី៖ អាចារ្យវត្តណា?
ឡុត៖ អាចារ្យវត្តអន្លង់វែងនេះឯង ។
ដានី៖ អាចារ្យវត្តអន្លង់វែង ឬវត្តអូរអង្រែ?
ឡុត៖ អាចារ្យវត្តអន្លង់វែង ។
ដានី៖ គាត់ចាស់ហើយឥឡូវ?
ឡុត៖ គាត់ចាស់គាត់ចង់៦០ហើយ ។
ដានី៖ ចឹង តា អៀម ឥឡូវគាត់ធ្វើអី?
ឡុត៖ តា អៀម សព្វថ្ងៃគាត់ធ្វើស្រែ ។
ដានី៖ គាត់អត់មានធ្វើការងារអីទេ?
ឡុត៖ អត់ទេ តា អៀម គាត់កាត់រំសាយហើយ ។
ដានី៖ ចឹងកងពល៩១២មានតែពីរវរសេនាធំហ្នឹងទេ?
ឡុត៖ មានពីរវរសេនាធំ មកបានគេរៀបចំក្រោយទៀត ។
ដានី៖ មាន៨៣-៨៤និង៨០ប៉ុន្មានទៀត?
ឡុត៖ មាន៥៣ ។
ដានី៖ វរសេនាធំ៥៣?
ឡុត៖ បាទ ។
ដានី៖ ពីណាគេ៥៣ជាប្រធាន?
ឡុត៖ ៥៣កាលនោះ មានតា ឆាន់, មាន តា យុត ខ្ញុំមិនច្បាស់ដែរ សួរមេឃុំបានច្បាស់ ។
ដានី៖ តា ឆាន់, តា យុត នៅណាឥឡូវ?
ឡុត៖ គាត់ទៅកោះកុងមួយសារមិនដឹងថាគាត់នៅណា នៅខាងប៉ៃលិនមិនដឹង ។
ដានី៖ តែវរសេនាធំ៥៣នេះមិនមែនមកពីខាងលោកពូទេ?
ឡុត៖ អត់ទេ ។
ដានី៖ មកពីខាងណាវិញ?
ឡុត៖ កាលនោះដកទៅជាមួយពួក តា ភាព ។
ដានី៖ ដកពីណាទៅ?
ឡុត៖ មិនដឹងដកពីខាងណាផង ។
ដានី៖ ៨០១?

ឡុត៖ មិនមែនទេ ។

ដានី៖ មិនមែនពួក៨០១ទេ?

ឡុត៖ ទេ មិនមែនទេ សួរមេឃុំបានដឹងអត្តភាពគាត់ ។

ដានី៖ ចឹងតា ភាព ហ្នឹងគេដកមកពី?

ឡុត៖ នៅជុំ៥៣ហ្នឹងទេ ខាងកងពល៩១២ មកប្រមូលគ្នាមកបានបង្កើតជាកងពល៩១២ ។

ដានី៖ តា ភាព ធ្វើប្រធាន៩១២ចុះអនុបន្ទុបន្ទាប់ពីតា ភាព?

ឡុត៖ តា ហេង មិនដឹងពីណាទេ ។

ដានី៖ តា ហេង ក្រែងគាត់ប្រធានវរៈ?

ឡុត៖ អនុវរសេនាធំហ្នឹងឯង បានគេដកមក៩១២ហ្នឹងមកបានដក តា ហេង មកកងពលដែរ ។

ដានី៖ តា ហេង មកកងពលដែរ?

ឡុត៖ តា ហេង តា គង់ ។

ដានី៖ តា ហេង តា គង់ តា គង់ ដំបូងគាត់នៅណា?

ឡុត៖ គាត់ទៅពីខាងនេះដែរ ។

ដានី៖ ពី៥៣ដែរ?

ឡុត៖ បាទ! ដកទៅចូលជាមួយពួក៨៣នោះ តែគេដូរលេខវរសេនាធំអស់ហើយ៥១-៥២-៥៣ ។

ដានី៖ ៥៣ តា យុត តា ឆាន់?

ឡុត៖ ៥១នេះមាន តា គង់ តា រ៉េត ។

ដានី៖ ៥១ តា គង់ តា រ៉េត ៥៣ តា ឆាន់ តា យុត ចុះ៥២?

ឡុត៖ ៥២ មាន តា អៀម តា ភ័ណ្ឌ តា ណូន ។

ដានី៖ តា អៀម តា ភ័ណ្ឌ តា ណូន គាត់នៅណាឥឡូវ?

ឡុត៖ តា ណូន គាត់ស្លាប់ហើយ តា ភ័ណ្ឌក៏ស្លាប់ ។

ដានី៖ នៅតែតាអៀម មួយទេ តា គង់ គាត់នៅ ។

ឡុត៖ បាទ ។

ដានី៖ ចឹង តារ៉េត?

ឡុត៖ តា រ៉េត ស្លាប់ហើយ ។

ដានី៖ ចឹង តា ហេង?

ឡុត៖ តា ហេង ស្លាប់ ស្លាប់តាំងពីនៅសង្រ្គាមនោះ ។

ដានី: ចឹងដល់ពេល តា ភាព ស្លាប់ទៅពីណាឡើងប្រធានកងពល?

ឡុត: ឡើង តា គង់ ។

ដានី: ចឹងឡើង តា គង់ មិនមែនឡើត តាហេងទេ?

ឡុត: តា ហេង គាត់ស្លាប់ដែរ ។

ដានី: ស្លាប់ជាមួយ តា ភាពដែរ?

ឡុត: បាទ ។

ដានី: តា ភាព គាត់ស្លាប់ដោយសារមូលហេតុអី?

ឡុត: តា ភាព គាត់ស្លាប់ហ្នឹងឈឺ តា ហេង ត្រូវមីន ។

ដានី: តា ហេង និត តា ភាព ពីណាស្លាប់មុន?

ឡុត: តា ហេង, តា ហេង ស្លាប់មុនបានប៉ុន្មានខែបាន តា ភាព ។

ដានី: ដល់ពេលនេះ តា គង់ ឡើងប្រធានកងពល?

ឡុត: ឡើង ។

ដានី: ឡើងឆ្នាំណាទៅ?

ឡុត: ឡើងឆ្នាំ៩០ប៉ុន្មានទេ គាត់ គាត់កាលនោះគាត់កាន់វរសេនាធំតែគាត់ជាប់ជាសាខាកងពល ដែលហ្នឹង តា គង់ ដល់ពេលអត់ តា ភាព ទៅបានគាត់ឡើង ។

ដានី: ចឹងពូថាមិញហ្នឹង ៨៣-៨៨ហ្នឹង តាំងពីជំនាន់តា សឿនទេ?

ឡុត: បាទ ។

ដានី: ចង់ តា សឿន គាត់បាត់ទៅណាទៅតាំងចេញពីកងពល៩១២ហ្នឹង?

ឡុត: តា សឿន គាត់រត់ទៅថៃ ។

ដានី: តា សឿន រត់ទៅថៃបាត់ទៅ?

ឡុត: បាទ ។

ដានី: ចឹងដល់ពេលលោកពូនៅក្នុងវរយៈសេនាតូចណា?

ឡុត: ខ្ញុំនៅ៨៣ហ្នឹងឯងតែដល់៥១-៥២ហ្នឹង ខ្ញុំនៅក្នុង៥២ ។

ដានី: ចឹងលោកពូគេចេញ៥១ហ្នឹងលោកពូចេញទៅក្នុងវរសេនាធំ៥១?

ឡុត: ខ្ញុំនៅ៥២ ។

ដានី: ៥២នៅជាមួយ តា អៀម?

ឡុត: បាទ ។

ដានី: លោកពូនៅក្នុងប្រធានមន្ទីរវរសេនាធំហ្នឹង?

ឡុត៖ បាទ ។

ដានី៖ ប្រធានមន្ទីរវរសេនាធំ៥២ ប្រជាជនក៏នៅក្នុងមន្ទីរហ្នឹងដែរ?

ឡុត៖ បាទ! ខាងមីង១ ប្រពន្ធកងទ័ព ។

ដានី៖ លោកពូគ្រាន់មើលការខុសត្រូវខាងមីង១ ប្រពន្ធកងទ័ពហ្នឹងទៅ?

ឡុត៖ បាទ!នៅមើលប្រពន្ធកងទ័ពខ្វះអង្ករខ្វះអី ជួនកាលទាក់ទងមកខាងលើ ។

ដានី៖ ដោយសារលោកពូធ្លាប់នៅគ្រប់គ្រងមីង១ចឹងដល់ពេលគេបែកជាភូមិមកពូមកគ្រប់គ្រងនៅភូមិហ្នឹង?

ឡុត៖ បាទ ។

ដានី៖ចុះខាង៥១ខាងអ្នកគ្រប់គ្រងនៅមន្ទីរវរសេនាធំ៥១ពីណាគេ?

ឡុត៖ កាលនោះបង លន់ ឬពីណាផងទេ?

ដានី៖ លន់?

ឡុត៖ លន់ មេភូម មកពីភូមិអូរកណ្តាលហ្នឹង ។

ដានី៖ ចឹងខាង៥៣?

ឡុត៖ ៥៣អត់ច្បាស់ដែលកាលនោះ សួរមេឃុំបានច្បាស់ ។

ដានី៖ លោកមេឃុំកាលហ្នឹងគាត់គ្រប់គ្រងនៅ?

ឡុត៖ គាត់នៅមន្ទីរកងពលហើយ ដល់គាត់ពិការខ្ញុំមកនៅជាមួយគាត់ កាលខ្ញុំនៅជាប់ជើងតាភាព ហៅមកដែលតែខ្ញុំខ្វិលមក ។

ដានី៖ ចឹងពេលលោកពូមកនៅនេះលោកពូអាចហៅមកខាងឃុំ?

ឡុត៖ នៅជាប់ជាមួយមេឃុំ ខ្ញុំខ្វិលមកខ្ញុំនៅតែនោះ ។

ដានី៖ កាលហ្នឹងតា ភាព ស្គាល់លោកពូច្បាស់ដែរ?

ឡុត៖ ស្គាល់ច្បាស់ ខ្ញុំប្រធានវរៈប្រធានកងធំកងពិសេសវរសេនាធំកាលនោះ ។

ដានី៖ ចឹងលោកពូធ្វើវរៈអីប្រធានកងពិសេស?

ឡុត៖ ប្រធានកងពិសេសប្រចាំវរសេនាធំ៤៣ ។

ដានី៖ ចឹងពូប្រធានកងពិសេសវរសេនាធំ៤៣?

ឡុត៖ បាទ ។

ដានី៖ កាលពីលោកពូមិនទាន់ពិការ?

ឡុត៖ បាទ ។

ដានី៖ កាលលោកពូស៊ើបការ កាលហ្នឹងលោកពូហ៊ានដែលដូចថាយើងអន់អាចដែរ?

ឡុត៖	បាទ ។

ដានី៖	ត្រូវស៊ីបការយើងស៊ីបការខ្លួនឯងតែម្តងអត់ឲ្យកូនចៅទៅស៊ីបការទេ?

ឡុត៖	ត្រូវយើងខ្លះគេខ្លះ ពេលណាត្រូវយើងទៅចង់ច្បាស់ខ្លួនយើង កាលជំនាននោះទំរាំមេៗឈានមុខទាំងអស់ត្រឹមវរសេនាតូច សុទ្ធតែដើរតួទាំងអស់ ។

ដានី៖	ចឹងបើយើងឡើងទៅវរសេនាធំកងពលទៅបានផុត?

ឡុត៖	បាទ ។

ដានី៖	ប៉ុន្តែប្រធានវរសេនាធំកងពលក៏មាននៅគ្រោះថ្នាក់ម្តងៗដែរ?

ឡុត៖	វាផុតពេលស៊ីបការអី បើពេលវាយក៏នៅពីក្រោយគេដែរ ពេលវាយនៅអត់ឆ្ងាយទេនៅត្រឹមប៉ុននេះ ។

ដានី៖	ហ្នឹងវរសេនាធំ?

ឡុត៖	បាទ ។

ដានី៖	ចឹងបើកងពល?

ឡុត៖	កងពលវរសេនាធំនៅជាមួយនិងគ្នា ។

ដានី៖	ចឹងកងពល៩១២នេះបង្កើតនៅឆ្នាំ៨២?

ឡុត៖	ប្រហែលជា៨២ ។

ដានី៖	បាទ! ៨២ហើយមានតែបីវរសេនាធំទេ មាន៥១-៥២-៥៣?

ឡុត៖	កាលហ្នឹងបើមិនពាក់កណ្តាល៨១-៨២ប៉ុណ្ណឹងឯង ។

ដានី៖	ចឹងលោកពូរៀបការឆ្នាំណាទៅ?

ឡុត៖	ខ្ញុំការប្រពន្ធឆ្នាំ៨២ដែរ ។

ដានី៖	ការឆ្នាំ៨២ដែលកាលហ្នឹងលោកពូពិការហើយ?

ឡុត៖	ពិការហើយ ។

ដានី៖	កាលហ្នឹងមីងគាត់ធ្វើអីដែរ?

ឡុត៖	៨២នោះការប្រពន្ធខ្ញុំមុនទេ គ្រួសារខ្ញុំសព្វថ្ងៃនេះទើបបានឆ្នាំ៩៦ ។

ដានី៖	ការឆ្នាំ៨២គ្រួសារលោកពូឈ្មោះ អីទៅ?

ឡុត៖	ឈ្មោះ យ៉ន ស្លាប់នៅឆ្នាំ៩៤ ។

ដានី៖	គាត់ស្លាប់ដោយសារមូលហេតុអីទៅ?

ឡុត៖	ឈឺ ។

ដានី៖	ពូមានកូនជាមួយគាត់ប៉ុន្មាននាក់?

ឡុតៈ កូននៅប្រពន្ធមុនទាំងអស់ ប្រពន្ធសព្វថ្ងៃនេះអត់មានទេ ។

ដានីៈ ឆ្នាំ៩៦ បានលោកពូរៀបការជាមួយគាត់មួយសារទៀត?

ឡុតៈ បាទ ។

ដានីៈ កាលហ្នឹងគាត់នៅណាទៅ?

ឡុតៈ នៅអង្គភាពជាមួយគ្នា ។

ដានីៈ ចឹងគ្រួសារលោកពូមុនឈ្មោះ យ៉ន ស្រុកកំណើតគាត់នៅណា?

ឡុតៈ អ្នកខាងជីក្រែងដែរ ។

ដានីៈ គាត់នៅអង្គភាពវរសេនាធំ៥២ដែរ?

ឡុតៈ បាទ ។

ដានីៈ ចឹងការប្រពន្ធលើកទី២ លោកពូអត់មានកូនចៅទៀតទេ?

ឡុតៈ បាទ ។

ដានីៈ ចឹងលោកពូ៨១-៨២ហ្នឹង អង្គភាព៩១២ នៅកន្លែង៨០៨ហ្នឹង?

ឡុតៈ បាទ ។

ដានីៈ នៅ៨០៨ដល់ពេលណាទៅ?

ឡុតៈ មើល៨៥មិនដឹងនៅមុខជាំ៤០ ។

ដានីៈ មុខជាំកាលហ្នឹងគេហៅ៤០?

ឡុតៈ ទេ ៤០នៅខាងកើតជាំ នៅ៤០ហ្នឹងហើយបានមកនៅមុខជាំយើងនេះ បើរៀបរាប់ទៅវាច្រើនណាស់ ។

ដានីៈ ចឹងកាលហ្នឹងកងពល៩១២ហ្នឹងមានទៅធ្វើការអីខាងក្នុងដែលអត់?

ឡុតៈ គេចុះទៅតើ?

ដានីៈ ចុះទៅខាងណាមុខព្រួញខាងណា?

ឡុតៈ ៩១២ច្រើនតែខាងលិចសៀមរាបហ្នឹង ។

ដានីៈ ប៉ែកខាងលិចសៀបរាម ទៅខាងណាទៅខាងលិចខាងឧត្តរមានជ័យ?

ឡុតៈ ទេ នៅខាងស្រុកហ្នឹង ស្រុកវ៉ារិន ស្រុកក្រឡាញ់ស្រុកពួក ស្រុកស្រីស្នំ ម៉ុំចុងកាលខាងខេត្តឧត្តរមានជ័យ ចាប់ពីលិចសៀមរាបមកទល់នេះ ។

ដានីៈ ហើយ តា ភាព គាត់ស្លាប់ឆ្នាំណាទៅ?

ឡុតៈ តា ភាព ស្លាប់ឆ្នាំ៩០ប៉ុន្មានទេ ខ្ញុំភ្លេចបាត់ហើយ ។

ដានីៈ ពេលឆ្នាំ៨០ជាងអីហ្នឹង?

ឡុតៈ ទេ ពេលគាត់ស្លាប់ខ្ទង់៩០ហើយ ។

ដានីៈ ៩០ពេលលោកពូរៀបការលើកទី២គាត់ស្លាប់ហើយនៅ?

ឡុតៈ គាត់ស្លាប់ហើយ ។

ដានីៈ ចឹងប្រពន្ធលោកពូស្លាប់ឆ្នាំ៩៨?

ឡុតៈ គាត់ស្លាប់ហើយ ។

ដានីៈ ៩០ប៉ុន្មាន?

ឡុតៈ បង ភាព បើមិនស្លាប់៩៣-៩២ ក្រោយគេបោះឆ្នោតសភាឆ្នាំ៩៣ហ្នឹង ខ្ញុំភ្លេចបាត់ហើយតា ភាព បើមិន៩៣-៩២ ប៉ុណ្ណឹងឯង បើប្រពន្ធកូនគាត់បានច្បាស់ ។

ដានីៈ ប្រពន្ធគាត់ឈ្មោះ ផៃ ហ្នឹង?

ឡុតៈ បាទ ។

ដានីៈ ចុះ តា ហេង?

ឡុតៈ បើមិនស្លាប់៩០-៩១វាអត់ចាំដែរ ។

ដានីៈ ដោយជាន់មីន?

ឡុតៈ បាទ ។

ដានីៈ ចឹងតា គង់ ទើបគាត់ឡើងកងពលចន្លោះ៩២-៩៣ដែរ ទេ?

ឡុតៈ បាទ! កាលហ្នឹង តា ភាព គាត់ស្លាប់ បានគាត់ឡើងប្រធាន កងពលដែលតែនៅរង ។

ដានីៈ ចឹងបន្ទាប់ពី តា គង់ គាត់ឡើងអនុ តា គង់មានពីណាទៀត?

ឡុតៈ មានតា រ៉េត តា សារឿន ខ្មោច តា សារឿន ។

ដានីៈ សា រឿនណាទៅ?

ឡុតៈ សា រឿន ស្លាប់បាត់ហើយ សា រឿន ប្តីយាយ ញ៉ី ប្រពន្ធគាត់នៅជេងភ្នំសព្វថ្ងៃ ។

ដានីៈ យាយ ញ៉ី នៅជើងភ្នំ ភូមិជនពិការហ្នឹង?

ឡុតៈ ភូមិជើងភ្នំ នៅទល់មុខផ្ទះ តា ធឿន ជំទប់ទី១ ជំទប់ទី១ ឃុំត្រពាំងប្រិយ ។

ដានីៈ ចាប ប៊ុនធឿន?

ឡុតៈ ហ្នឹងហើយ ចាប ប៊ុនធឿន ។

ដានីៈ ចឹង តា រ៉េត គាត់នៅ ឬមួយស្លាប់ហើយ?

ឡុតៈ ស្លាប់ហើយ ។

ដានីៈ ចឹងឋានៈកងពលនៅតែ តា គង់ មួយ?

ឡុតៈ បាទ ។

ដានី៖	ចឹងលោកពូមកនៅមុខដាំហ្នឹងរហូតដល់ពេលណាទៅ?

ឡុត៖	នៅមុខដាំនេះឆ្នាំ៩០ បានចុះមកនៅលំទងចាស់នេះ ដែលវាយដាច់អន្ទង់វែងមកដាក់ចុះមកក្រោមមកនៅលំទងចាស់ ។

ដានី៖	ចឹងអគ្គភាព៩១២ចុះទៅនៅលំទងចាស់នៅហ្នឹង?

ឡុត៖	បាទ ។

ដានី៖	ចឹងយ៉ាងម៉េចបានដាមិននៅនេះ លំទងថ្មីនៅកុងមិញនេះ?

ឡុត៖	កាលនោះគេផ្សេងតាមកងពល ។

ដានី៖	កងពលណាទៅ?

ឡុត៖	អន្ទង់វែងហ្នឹង៩៨០ កងពល៧៨៥ ។

ដានី៖	ហើយដល់៩១២?

ឡុត៖	៩១២ទៅនៅលំទង ។

ដានី៖	ខាងកុងមិញនេះមានពីណានៅវិញ?

ឡុត៖	កន្លែងផ្ទះមេឃុំនៅសព្វថ្ងៃកាលនោះ កន្លែងអ្នកពិការ តា សេង ។

ដានី៖	ចឹងតាំងពីលោកពូពិការមក លោកពូនៅមន្ទីរកងពលហ្នឹងអត់ដែលចុះទៅធ្វើការអីខាងក្នុងទេកាលហ្នឹង?

ឡុត៖	អត់ទេ ។

ដានី៖	យើងនៅតែកងពលយើងមើលតែមីង១ ចុះសម្ភារស្បៀងអីនៅលើពូដែរ?

ឡុត៖	បាទ!យើងដោះស្រាយស្បៀង ។

ដានី៖	សម្រាប់ដោះស្រាយស្បៀងអីទៅ លោកពូស្បៀងយើងទៅយកពីកងពល ឬយើងទៅយកពីឃ្លាំងធំមក?

ឡុត៖	នេះយើងទាក់ទងតាមកងពលទៅ កងពលគេគេទៅ តា ម៉ុក ឡើងដឹក ។

ដានី៖	ចឹងទាក់ទងនៅលោកពូមេឃុំ?

ឡុត៖	បាទ! មេឃុំគាត់ជាអ្នកទទួលរួម ខ្ញុំនៅតាមមន្ទីរវរសេនាធំចេះ ទាក់ទងទៅមេឃុំ ។

ដានី៖	ចឹងទាក់ទងទៅលើទៅគេដឹកយកមកឲ្យ?

ឡុត៖	បាទ!គេដឹកយកមកឲ្យ ។

ដានី៖	ចឹងឆ្នាំ៩០ អគ្គភាពលោកពូចុះមកនៅលំទងចាស់ហើយ?

ឡុត៖	បាទ ។

ដានី: គេបែកទីតាំងគ្នានៅយ៉ាងម៉េចទៅអាហ្នឹង ហេតុអីបានជាអ្នកខ្លះនៅអន្លង់វែងអ្នកខ្លះទៅនៅខាងថ្ងៃគ អ្នកខ្លះមកនៅហ្នឹងអីចឹង?

ឡុត: ខ្លះណាបែកគ្នានៅដើម្បីយកដីយកធ្លី ព្រោះនៅមែនទែន ព្រោះថាអាចថាស្រុកជិតចប់ហើយ តាមការស្មានទេ ដល់ចុះមកខ្មោច តា ម៉ុក នេះគាត់ឲ្យមេៗកងពលជ្រើសរើសដីទៅ កន្លែងណាដីល្អ ។

ដានី: ចឹងនៅពេលលោកចុះមកនៅលំទងចាស់ឆ្នាំ៩០ហ្នឹងនៅជាមួយប្រជាជនចាស់គេនៅហ្នឹង?

ឡុត: ប្រជាជនអ្នកលំទងចាស់ក៏រត់ឡើងភ្នំអស់ដែរ អត់មានអ្នកភូមិចាស់នៅទេ នៅលើភ្នំជុំគ្នាទាំងអស់ ។

ដានី: តែអង្គភាពលោកពូ៩១២ចុះទៅហ្នឹង ទៅនៅភូមិលំទងចាស់ហ្នឹងប្រជាជនមកនៅនោះដែរ?

ឡុត: បាទ! ចុះមកនៅនោះដែរ ។

ដានី: ចឹងកាលហ្នឹងអង្គភាព៩១២ចុះមកហ្នឹងមានប៉ុន្មានទៅ បើគិតជាកងទ័ពគិតជាគ្រួសារសរុបទៅប្រហែលជាប៉ុន្មាននាក់ទៅ?

ឡុត: តែខ្ញុំភ្លេចពីស្ថិតិអស់ហើយ ។

ដានី: អាចថាដល់ពាន់នាក់ទេ?

ឡុត: មិនដល់មួយពាន់គ្រួសារទេ ។

ដានី: ប្រហែលជាប៉ុន្មានគ្រួសារ?

ឡុត: ប្រហែលជា៨០០គ្រួសារ ។

ដានី: អាចថាតិចជាងហ្នឹង ឬច្រើនជាងហ្នឹង?

ឡុត: មិនតិចមិនច្រើនប្រហែលតែប៉ុណ្ណោះ ។

ដានី: ចឹងចុះមកនៅក្នុងភូមិលំទងចាស់ហ្នឹងនៅតែក្នុងមួយភូមិមួយហ្នឹងទេ?

ឡុត: បាទ! នៅហែរគ្នាចាប់ពីក្រោលគោនេះទៅរហូតដល់អូរលាងសេះ ហើយបានមាននៅមួយផ្លូវអីនៅពីមុខពីក្រោយគ្នា ។

ដានី: នៅជាគ្រួសារៗចឹងទៅ?

ឡុត: បាទ ។

ដានី: ពេលដែលឆ្នាំ៩០ចុះមកហ្នឹងកាលហ្នឹងគេមានបែកជាមេឃុំអីហើយនៅ?

ឡុត: កាលហ្នឹងមានរៀបដែលតែរៀបវាមិនច្បាស់លាស់ តា គ្រាន់តែរៀបគំរោងរបស់គាត់ ។

ដានី: ចឹងគ្រាន់តែរៀបគំរោងទេ នៅលំទងចាស់បានរយៈពេលប៉ុន្មាន?

ឡុត: មានចេះដែរ តា សេង ពិការនៅកុងមិញនេះ រៀបចជាស្រុក ពួកខ្ញុំនៅលំទងនោះរៀបចំជាឃុំទៅ ។

ដានី: ចឹងតា សេង នេះហ្នឹងគាត់រៀបចំជាស្រុក?

ឡុត: បាទ ។

ដានី: តា សេង ឥឡូវគាត់នៅអូរអង្ក្រែហ្នឹង?

ឡុត: បាទ ។

ដានី: ចឹងកន្លែងលោកពូរៀបចំជាឃុំកាលហ្នឹងពីណាទទួលកាលហ្នឹង?

ឡុត: មេឃុំសព្វថ្ងៃនេះ ។

ដានី: គាត់ទទួលមេឃុំតាំងពីជំនាន់នោះមក?

ឡុត: បាទ ។

ដានី: ចឹងលោកពូកាលនៅហ្នឹងយើងទទួលជាភូមិជាផ្នែកៗហើយនៅ?

ឡុត: ទទួលតាមវរសេនាធំនេះឯង តាមវរសេនាតូចទៀត ។

ដានី: លោកពូនៅលំទងចាស់ហ្នឹងបានយូរទេ?

ឡុត: មកនៅលំទងចាស់តាំងពី៩០មកទល់៩៨ ដែលខាងរដ្ឋកម្ពុជាវាយបានរត់ចេញទៅជើងភ្នំ ។

ដានី: ចឹងកាលហ្នឹងខាងរដ្ឋាភិបាលវាយរត់មកជើងភ្នំ?

ឡុត: បាទ ។

ដានី: ហើយយ៉ាងម៉េចទៀតទៅ?

ឡុត: នៅជើងភ្នំបានពីរឆ្នាំទៅបីឆ្នាំបានពីរឆ្នាំមកនៅនេះឆ្នាំ៩៧ខ្ញុំមកនៅនេះ ។

ដានី: ចឹងឆ្នាំ៩៧អត់មានទៅលំទងទេ មកនៅនេះតែម្តង?

ឡុត: អត់ ទាំងអ្នកលំទងចាស់អីក៏អត់ទៅ គេមិនទាន់ឲ្យទៅខ្លាចសភាពការណ៍ ។

ដានី: និយាយឆ្នាំ៩៧ត្រឡប់មកនេះគេហៅអីដបូង?

ឡុត: នៅនេះតា ដំបូងគាត់ឲ្យដាក់ឈ្មោះ វាលវែង តែអន្តភាព៥២ដដែល ។

ដានី: ចឹងកាលហ្នឹង៩១២មកនៅវាលវែងទាំងអស់?

ឡុត: ទេ ខ្លះទៅនៅហ្នឹងវិញ ។

ដានី: ចឹងដល់ឆ្នាំ៩៧ត្រឡប់មកនៅហ្នឹង?

ឡុត: បាទ!មកនៅហ្នឹង ។

ដានី: ចឹងនៅភូមិវាលវែងហើយមានហួសភូមិវាលវែងទៀត?

ឡុត: អត់មានទេ ផុតត្រឹមភូមិខ្ញុំនេះហើយ ។

ដានី៖ ចឹងផុតត្រឹមភូមិវាលវែងហ្នឹង?

ឡុត៖ បាទ ។

ដានី៖ ចឹងកុងប៉ិញដល់វាលវែង ចឹងលោកពូមានដឹងប្រវត្តិកុងប៉ិញហ្នឹងស្អីគេកុងប៉ិញហ្នឹង?

ឡុត៖ ទេ! កុងប៉ិញនេះចាស់ៗកាលពីដើមហៅអូរចិញ្ចៀនទេ តែដល់ថាជំនាន់នោះមានបន្ទាយយួននៅនោះ គេហៅបន្ទាយកុងប៉ិញគេ ។

ដានី៖ ចឹងជាប់ឈ្មោះ បន្ទាយកុងប៉ិញចឹងទៅ?

ឡុត៖ បាទ ។

ដានី៖ ចឹងកាលហ្នឹងឆ្នាំ៩៧មិនទាន់រៀបចំជាភូមិអី ច្បាស់លាស់នៅកាលហ្នឹង?

ឡុត៖ នាំគ្នានៅហែរបេះឯងតាមបង្គំដី កាលហ្នឹងធ្វើស្រែបានមួយវស្សានោះក៏ត្រូវគេព្រឹត្តិការណ៍អន្លង់វែងនេះទៅរត់ទៅទៀតទៅនៅភូណយ ឆ្នាំ៩៩បានចុះមកនេះវិញ ។

ដានី៖ ចឹងឆ្នាំ៩៧ហ្នឹងនៅបានមួយវស្សាទេបានមួយឆ្នាំអត់?

ឡុត៖ ធ្វើស្រែបានមួយឆ្នាំ ។

ដានី៖ ចឹងរត់ហ្នឹងរត់ឆ្នាំ៩៨ចឹង?

ឡុត៖ បាទ! រត់ឆ្នាំ៩៨ ព្រឹត្តិការណ៍បែកមានតា ជាន់ជាចៅហ្វាយស្រុក ។

ដានី៖ ព្រឹត្តិការណ៍បែកទៅ?

ឡុត៖ នៅភូណយមួយឆ្នាំដែរ ។

ដានី៖ ចឹង៩១២ទៅភូណយទាំងអស់?

ឡុត៖ បាទ ។

ដានី៖ ៩៩ត្រឡប់មកវិញ តែសមាហរណកម្មមិនឆាំ៩៨?

ឡុត៖ ៩៨ពួកគេទៅខាងបែកាប់នេះ៩៩បានយើងធ្វើសមាហរណ៍កម្ម៩៨ពួក តា ជាន់គាត់ទៅខាងនោះ ៩៨ហ្នឹងយើងជិតត្រូវគ្នាហើយ៩៩បានមកជួបជុំគ្នានេះវិញ ។

ដានី៖ ៩៩ត្រឡប់មកវិញ?

ឡុត៖ បាទ! ខែ១ឆ្នាំ៩៩ ។

ដានី៖ ចឹងខែ១ឆ្នាំ៩៩ចុះមកវិញ កាលហ្នឹងជំនារខាងហ្នឹងគេអត់មានចាប់យកដី?

ឡុត៖ អត់ទេ តែនៅមកុងប៉ិញនោះយកគោ ពួកតា ជៀវ ដល់ស្រុកស្រលបួលគ្នាវិញហើយគេទៅភូមិចាស់គេវិញទៅ ។

ដានី៖ ហើយក៏យើងយកទៅ?

ឡុត៖ បាទ! យកហើយលក់ឲ្យគេខ្វះ ។

ដានី:	លក់ឲ្យគេខ្លះដែរ?

ឡុត:	បាទ! អ្នកខ្លះលក់អ្នកខ្លះអត់ ។

ដានី:	តែខាងកងពលអីនៅក្នុងបិញទៅ?

ឡុត:	បាទ ។

ដានី:	ហើយតាមវរៈៗហ្នឹងមកនៅតាមហូរហែរមក?

ឡុត:	បាទ ។

ដានី:	ចឹងមន្ទីរកងពលទេ ច្រើនតែនៅក្នុងបិញច្រើនតែមន្ទីរកងពលរបស់ពូមេឃុំឥឡូវហ្នឹងទេ កន្លែងក្នុងបិញកន្លែងលំនៅថ្មីហ្នឹង?

ឡុត:	បាទ! ដែលមកដើងភ្នំវិញហ្នឹង៥២នៅនេះទៅ៥ ១នៅនោះទៅ ។

ដានី:	៥ ១នៅណា?

ឡុត:	៥ ១នៅខាងអូរគគីរកណ្តាល ។

ដានី:	ហើយ៥ ៣?

ឡុត:	៥ ៣ជាប់គ្នាខាងនោះឯង ។

ដានី:	ហើយភូមិលំនៅចាស់អ្នកភូមិចាស់គេទៅ?

ឡុត:	បាទ! ទេកាលនោះលំនៅចាស់មិនទាន់ទៅទេ ។

ដានី:	ចឹងលោកពូយើងចាប់ផ្តើមដាក់ឈ្មោះជាភូមិអីចាប់ផ្តើមពីពេលណាមក?

ឡុត:	ដែលដាក់ឈ្មោះអូរគគីរក្រោមហ្នឹង ។

ដានី:	បាទ ។

ឡុត:	អូរគគីរក្រោមទើបដាក់ឆ្នាំ៩៩នេះឯង លោកមេឃុំភា គាត់ជាអ្នកដាក់ ។

ដានី:	លោកមេឃុំ បូ ភា ហ្នឹង?

ឡុត:	កាលនោះ បូ ភា គាត់ជាមេឃុំ បូ ភា គាត់ទៅបែតាប់ពួកខ្ញុំទៅភូណយ ដូចចូលកាលសម័យបីឆ្នាំដែរ គេផ្តាច់ខ្លួនមុនគេធ្វើមេ ហើយមេឃុំនេះទើបបោះឆ្នោតក្រោយនេះទេ ។

ដានី:	ហើយ បូ ភា ហ្នឹងគាត់ទៅជាជំទប់ទីមួយហ្នឹងទៅ?

ឡុត:	បាទ ។

ដានី:	ដាក់ឈ្មោះ ដាក់អីហ្នឹងលោកជំទប់ទី១កាលហ្នឹង កាលអណ្តិតគាត់មេឃុំហ្នឹងគាត់ជាអ្នកដាក់ឈ្មោះទេ?

ឡុត:	បាទ! បើសិនជាគាត់ប្រាប់ខ្ញុំមិនបានដាក់អូរគគីរក្រោមដែរ ខ្ញុំដាក់ថាវាលវែងវិញ ខំដាក់អូរគគីរ ឡើងបីប្អូនដាន់ ។

ដានីៈ ចឹងអ្នកដាក់ឈ្មោះ ភូមិឃុំ គឺលោក បូ ភា កាលហ្នឹងគាតលអតីតមេឃុំ បច្ចុប្បន្នជាជំទប់ទី១ គាត់ជាអ្នកខ្លួនគាត់ចឹងតែម្តង?

ឡុតៈ បាទ ។

ដានីៈ ចឹងលំទង់ថ្មីគាត់អត់មានពីគ្រោះជាមួយពីណាគាត់ដាក់ដោយខ្លួនគាត់ដែរ?

ឡុតៈ ខ្ញុំមិនបានដឹងដែរ ។

ដានីៈ ចឹងកាលធ្វើជាមេឃុំពីណាគេបន្ទាប់ៗគាត់?

ឡុតៈ កាលនោះ ឆាន ។

ដានីៈ កាលនោះ បូ ភា មេឃុំ ជំទប់ទី១ ឈ្មោះ ឆាន ឆានដែលគាត់ជាប្រធានវរសេនាធំ?

ឡុតៈ អត់ទេ ឆាន មិនមែនជាប្រធានវរសេនាធំទេ ។

ដានីៈ មានឈ្មោះ ភា ឈ្មោះ ឆាន ហើយមានពីណាទៀត?

ឡុតៈ ឈ្មោះ ស្រៀន ស្រៀនហ្នឹងឡប់ខ្លៃទៅណាបាត់ហើយ កាលមេឃុំចាស់នោះកាលហ្នឹងមានជំទប់លេខ១ និងជំទប់លេខ២ ។

ដានីៈ មានតែបីនាក់ទេ?

ឡុតៈ មានតែបីហ្នឹងឯង ។

ដានីៈ ហើយដាក់ឈ្មោះ ភូមិហ្នឹងគាត់ទេ ជាអ្នកដាក់ឈ្មោះដំបូង?

ឡុតៈ បាទ ។

ដានីៈ លោក បូ ភា ទេ ជាអ្នកដាក់?

ឡុតៈ បាទ ។

ដានីៈ ដាក់ភូមិលំទង់ថ្មី ដាក់អូរគគីរក្រោម អូរគគីរលើ អូរគគីរកណ្តាលហ្នឹងគាត់អ្នកដាក់ទេ?

ឡុតៈ បាទ ។

ដានីៈ គាត់ដាក់ផ្អែកទៅលើស្អីបានជាគាត់ដាក់ហ្នឹង?

ឡុតៈ គាត់ផ្អែកនៅតាមបណ្តោយអូរនេះដឹង ព្រោះអូរនេះគេហៅអូរគគីរ ។

ដានីៈ តែបើសិនជាលោកដឹង លោកពូមិនឲ្យដាក់ចឹងទេ ដាក់វាលវែងទេ?

ឡុតៈ ដាក់ភូមិវាលវែងវិញ កុំឲ្យជាន់គ្នាច្រើនពេក ។

ដានីៈ កុំឲ្យមានអូរគគីរច្រើនពេក?

ឡុតៈ បាទ! វាលវែង ឬមួយដាក់គោកយាងទៅ កាលហ្នឹងពីដើមមិញសប្បូរដើមឈើទាល ដើមយាង ។

ដានីៈ ដើមឈើទាលយ៉ាងម៉េចបានគេហៅដើមយាងចឹង?

ឡុត: ស្រុកគេហៅយាន ។

ដានី: ស្រុកនៅណាស្រុកសៀមរាបហ្នឹង?

ឡុត: បាទ ។

ដានី: បើឈើទាលគេអ្នកខាងក្រោម?

ឡុត: បាទ ។

ដានី: ខ្ញុំស្គាល់តែឈើទាលហៅយានអត់ដឹងទេ?

ឡុត: បាទ ។

ដានី: តែបើដាក់យានក៏ជាន់ជាមួយខាងឃុំអន្លង់វែងនោះវិញ យានដើងដើងត្បូងណា ចឹងគេដាក់ហ្នឹងលោកពូអត់មានបានរួមពិភាក្សាទេ?

ឡុត: អត់ទេ! តែខ្ញុំរកកែតែកែមិនបាន ។

ដានី: ចឹងកាលហ្នឹងមានប៉ុន្មានភូមិកាលយើងមកឆ្នាំ៩៩ដំបូងហ្នឹង?

ឡុត: កាលឆ្នាំ៩៩ហ្នឹងដឹងមានប៉ុន្មាន អត់ស្រឡៅស្រោង អត់សំព័រ អត់ចារប៉ុណ្ណោះឯង ។

ដានី: ចុះមាន៦ភូមិកាលនោះ?

ឡុត: បាទ! មាន៦ភូមិកាលនោះ ។

ដានី: មានភូមិទួលទ្រៀស លំទងថ្មី គគីរលើ គគីរក្រោម គគីរកណ្តាល លំទងចាស់ មាន៦ភូមិ ចឹងទួលទ្រៀសគេផ្អែកទៅលើអីបានគេដាក់ទួលទ្រៀស?

ឡុត: កាលហ្នឹងដើមទ្រៀសវាច្រើន ។

ដានី: ភូមិហ្នឹងមានពីឆ្នាំ៩៩មកដែរ?

ឡុត: ពីមុននៅដែលតែទើបដាប់ ។

ដានី: ចឹងលោកពូដំបូងពីឆ្នាំ៩៩ដូចថា មានប៉ុន្មានគ្រួសារទៅបងប្អូនយើងអតីតដែលចុះមក?

ឡុត: ៩៩មាន៥០ប៉ុន្មានទេ ៥៧-៥៨គ្រួសារតែប៉ុណ្ណឹងឯង ។

ដានី: មានតែ៥៧-៥៨គ្រួសារទេ បើគិតពីចំនួនមនុស្សមានប៉ុន្មានទៅ?

ឡុត: ខ្ញុំភ្លេចបានហើយខ្ទង់៣០០នាក់ ។

ដានី: ដល់ឥឡូវមានប៉ុន្មានទៅ?

ឡុត: ឥឡូវមាន១២២គ្រួសារ ចំនួនមនុស្សមាន៥១៣ ។

ដានី: ១២២ចំនួនមនុស្សមាន៥១៣នាក់ចឹងកើនដាងពាក់កណ្តាលហើយចឹង ឥឡូវ១២២គ្រួសារមាន៥១៣កាលមុនមាន៥៨គ្រួសារម៉េចមានមនុស្សដល់៣០០?

ឡុត: បើមិនដល់៣០០ក៏ខ្ទង់២៩០ដែរ តែសព្វថ្ងៃមនុស្សច្រើនគ្រួសារមនុស្សវានៅដដែល ។

ដានី៖ ចឹងមានន័យបំបែក?

ឡុត៖ បាទ ។

ដានី៖ ចឹងដោយសារមានកូនការទៅយើងបំបែកគ្រួសារទៅ?

ឡុត៖ បាទ ។

ដានី៖ តែមានអ្នកថ្មីចូលមករស់នៅច្រើនដែលអត់?

ឡុត៖ ចូលតិចទេ ភូមិនេះ ។

ដានី៖ ភាគច្រើនចាស់ៗ?

ឡុត៖ បាទ ។

ដានី៖ ចឹងដូចថាដីភូមិផ្ទះសំបែងយើងចែកគ្នាយ៉ាងម៉េចទៅ ដូចថាផ្ទះភូមិដីស្រែដីអី?

ឡុត៖ ដីស្រែចាប់រាងខ្លួន ដីភូមិដែលនៅនេះចែកគ្នាកាលពីសម័យ តា ដែលនៅកាលឆ្នាំ៩៧នោះ ចែកគ្នា ។

ដានី៖ ចែកគ្នាតាំងពីសម័យ តា មក?

ឡុត៖ បាទ ។

ដានី៖ ដល់ពេលដីស្រែដីចម្ការយើងហែកខ្លួនឯង ឬយ៉ាងម៉េច?

ឡុត៖ យើងកាប់រាងខ្លួន ។

ដានី៖ ចឹងអ្នកណាមានកម្លាំងច្រើនទៅ កាប់ហែកបានច្រើនហិចតាទៅ បើយើងអត់សូវមានកម្លាំង យើងសុខភាពមិនល្អក៏ហែកមិនសូវបានច្រើនដែរ?

ឡុត៖ បាទ ។

ដានី៖ បើដីភូមិបានគេចែក បានបណ្ដោយប៉ុន្មានទទឹងប៉ុន្មានទៅ?

ឡុត៖ កាលនោះបានទទឹង៤០ បណ្ដោយ២០០ តែដល់ម៉ែត្រដាក់ស្ដែងខ្លះបានតែ៥០កាលនោះ យើងវាស់ម៉ែត្រឈើយើង ដល់វាស់ម៉ែត្រយើងត្រឹមត្រូវធ្វើចុងសន្ទឹកហ្នឹងមាន៥០និង ៥០លើស ខ្លះ៤៧-៤៨ ។

ដានី៖ កាលនោះយើងវាស់ស្មានៗមានលើស?

ឡុត៖ កាលហ្នឹងដីវាគ្មានតម្លៃ មានពីណាទៅប្រិតប្រៀងប៉ុន្មាន ។

ដានី៖ ចឹងដលពេលបណ្ដោយ?

ឡុត៖ បណ្ដោយមាន២០០ ។

ដានី៖ អាចមានលើស២០០ទៀត?

ឡុត៖ ខ្លះលើស ពួកខាងនេះខ្លះខ្វះ ចាលអូរ ដូចខ្ញុំត្រង់នេះអត់បាន២០០ទេ ចាលអូរ ។

ដានី៖ តែលោកពូបាននៅមុខគេ?

ឡុត៖ បាទ ។

ដានី៖ ចឹងលោកពូកាលពីព្រឹត្តិការណ៍ឆ្នាំ៩៧ហ្នឹងមិនមាន ព្រឹត្តិការណ៍ច្រើនដូចខាង ដូចជា តា ប៉ុល ពត អី ហើយ តា ម៉ុក គាត់បែកបាក់គ្នា គាត់ឈ្លោះគ្នាអីកាលហ្នឹងមានមូលហេតុអី បានជាបែកបាក់គ្នា?

ឡុត៖ កាលហ្នឹងខ្ញុំមិនបានដឹងដែរ មិនថាមូលហេតុអី ។

ដានី៖ ដូចជាតា ប៉ុល ពត អីយ៉ាងម៉េចកាលហ្នឹង?

ឡុត៖ តា ប៉ុល ពត គាត់ចង់ធ្វើអធិរាជតែគាត់ ។

ដានី៖ គាត់ចង់ធ្វើអធិរាជ?

ឡុត៖ បាទ! តែគោលការណ៍កាលនោះការប៉ាន់ស្មានរបស់ខ្ញុំទេ វាមិនជាកស្តែងទេខ្ញុំប៉ាន់ប្រមាណ ទៅ តា ម៉ុក គាត់ចង់បង្រួបបង្រួម ព្រោះមើលការចរចារនៅភូមិចារ តា ម៉ុក ឲ្យទៅចរចារ តា ប៉ុល ពត គាត់ជាអ្នករៀបចំផែនការកំទេចចោល ការចរចារហ្នឹង ។

ដានី៖ ចឹងចរចាររឿងអី?

ឡុត៖ ចរចារជាមួយសម្តេច ហ៊ុន សែន ។

ដានី៖ ចឹងមានការចរចារនៅភូមិចារ?

ឡុត៖ បាទ ។

ដានី៖ ដល់ពេល តា ប៉ុល ពត គាត់រៀបផែនការកំទេច?

ឡុត៖ រៀបផែនការកំទេច ។

ដានី៖ កំទេចយ៉ាងម៉េចទៅមានស្លាប់មានអីដែលអត់?

ឡុត៖ ស្លាប់អស់គ្នាប៉ុន្មាននាក់ ។

ដានី៖ កាលហ្នឹងថាមានយន្តហោះអីមកហ្នឹង?

ឡុត៖ បាទ ។

ដានី៖ ចឹងកាលយន្តហោះមកហ្នឹងខាង តា ប៉ុល ពត ទេជាអ្នកកំទេច?

ឡុត៖ បាទ ។

ដានី៖ ពីណាជាអ្នកដឹកនាំកម្លាំងទៅកំទេច?

ឡុត៖ តា សារឿន ។

ដានី៖ តា សារឿន តា០៥ហ្នឹង?

ឡុត៖ បាទ ។

ដានីៈ	កាលហ្នឹងមានស្លាប់ប៉ុន្មាននាក់?

ឡុតៈ	ខ្ញុំមិនដឹងដែរ ។

ដានីៈ	ការចរចារហ្នឹងនៅណា ភូមិចារនៅណាទៅ ភូមិចារជិតរហាលហ្នឹង?

ឡុតៈ	បាទ ។

ដានីៈ	ជិតទំនប់ថ្មីហ្នឹង?

ឡុតៈ	បាទ! ជិតអីឆ្ងាយគ្រាន់ដែរ តែមិនភូមិចារថ្មីសព្វថ្ងៃទេ ភូមិចារចាស់ នៅខាងនោះចារថ្មី ។

ដានីៈ	ចឹងកាលហ្នឹងយន្តហោះគេមកចរចារចុះនៅហ្នឹង?

ឡុតៈ	ចុះនៅហ្នឹង ។

ដានីៈ	ដល់ពេលចុះមក ប៉ុល ពត រៀបចំឲ្យតា សារឿន ទៅកំទេច?

ឡុតៈ	បាទ ។

ដានីៈ	ទៅកំទេចហ្នឹង កំទេចតែខាងក្នុងទេ ខាងតា ម៉ុក អត់មានអីទេ?

ឡុតៈ	បាទ! ដលមានការចរចារនៅប្រាសាទព្រះវិហារទៀត កើតមានរឿងធំតែម្តងវាយគ្នាតែម្តងកាលហ្នឹង ។

ដានីៈ	វាយគ្នាជាមួយ តា ម៉ុក និង តា ប៉ុល ពត ហ្នឹង?

ឡុតៈ	បាទ ។

ដានីៈ	ពេលគេចាប់បានតា ប៉ុល ពត កាត់ទោស តា ម៉ុក ចាប់បានពេលកាត់ទោសអីហ្នឹងពូមានបានចូលរួមបានដឹងរឿងរ៉ាវហ្នឹងទេ?

ឡុតៈ	ខ្ញុំអត់បានទៅទេ ថ្ងៃគេកាត់ទោសមានបារាំងមានអាមេរិកគេមក ខ្ញុំមិនបានទៅទេ ។

ដានីៈ	តែមានបានដឹងរឿងរ៉ាវខ្លះដែរ?

ឡុតៈ	ដឹងថាគេកាត់ទោសមានបារាំងមានអាមេរិចអី ។

ដានីៈ	ចឹងខាង តា ម៉ុក ចាប់ខាង តា សារឿន តា សាន ០៥ -០៦អីហ្នឹងចាប់មេកងពលផ្សេងៗទៀតអីហ្នឹង កាលហ្នឹងយ៉ាងម៉េចដែលគេចាប់ហើយបានជាដល់ថ្នាក់សម្លាប់អីហ្នឹង?

ឡុតៈ	អានោះខ្ញុំក៏វាមិនដឹងរឿងដែរ ។

ដានីៈ	ចឹង តា សុន សេន ដែលគេសម្លាប់ទាំងគ្រួសារអី?

ឡុតៈ	តា សុន សេន ពួក តា សារឿន អីសម្លាប់ ខ្ញុំឮតាមគេដែរ មានកន្លែងតា ប៉ុល ពត នោះ តា ម៉ុក តា ប៉ុល ពត មានផែនការសម្លាប់ តា ម៉ុក និង តា សុន សេន យប់នេះឯង តា ម៉ុក ហៅតា សុន សេន នោះ តា សុន សេន ឲ្យតា ម៉ុក ចុះមកមុន ចុះមកមុនបានជាប់ តា សុន សេន ។

ដានី៖ ដឹងថា តា ម៉ុក រៀបផែនការកំទេច?

ឡុត៖ ដឹងថា តា ប៉ុល ពត រៀបចំផែនការកំទេច ព្រោះមានអ្នកត្រូវជាមួយតា ម៉ុក ខ្លះដែរ ។

ដានី៖ ពីណាគេបើតាមពូដឹង?

ឡុត៖ មិនដឹង ខ្ញុំស្តាប់តាមគេអ្នកនិយាយ ។

ដានី៖ ស្តាប់ពីណាគេនិយាយហ្នឹង?

ឡុត៖ គេអ្នកធំៗខាងលើគេនិយាយ ។

ដានី៖ អ្នកដឹងរឿងហ្នឹងច្បាស់ពីណាគេទៅ?

ឡុត៖ មិនដឹងដែរ ។

ដានី៖ បាទ! ព្រោះនេះជាព្រឹត្តិការណ៍មួយសំខាន់ដែរ ដែលយើងត្រូវការចង់ដឹងដើម្បីយកទៅសរសេរសៀវភៅលោកពូ?

ឡុត៖ អានេះបើសួរមេៗកងទ័ព ។

ដានី៖ សួរ តា គង់ អី?

ឡុត៖ បាទ! គាត់ច្បាស់ដូចខ្ញុំអីនេះនៅដាច់ស្រយាលសឹងថា ឆ្ងាយបន្តិច ។

ដានី៖ ចឹងលោកពូស្គាល់ តា ម៉ុក ច្បាស់ទេ?

ឡុត៖ ស្គាល់ច្បាស់តើ ។

ដានី៖ តា ម៉ុក មនុស្សរាងរៅគាត់យ៉ាងម៉េចហើយ អត្តចរិកគាត់យ៉ាងម៉េចវិញ តាមលោកពូស្គាល់គាត់?

ឡុត៖ ចាប់ពីពេលដែលខ្ញុំស្គាល់មក ខ្ញុំស្គាល់សម័យដែលខ្ញុំចូលស្រុក កាលពីដើមមិញពូថា តា ម៉ុក គាត់កាច កាលដែលខ្ញុំស្គាល់គាត់មក គាត់មិនមែនជាមនុស្សកាចទេ គាត់កាចគាត់ដែរមែន ដូចថាម៉ែឪដែរប្រដៅកូន ដែរឲ្យយើងរកឲ្យយើងថា រកសុំអីឲ្យតែមានមិនដែលថាទេ តែកាលសម័យបីឆ្នាំខ្ញុំមិនបានដឹងទេ ខ្ញុំមិនដែលស្គាល់គាត់ទេ ។

ដានី៖ ចឹងលោកពូកូនចៅជំនាន់ក្រោយៗអី គេឮឈ្មោះ តា ម៉ុក អីចឹងគេមកសួរលោកពូ សួរពីលោកពូរឿង តា ម៉ុក ហើយពូអាចប្រាប់ទៅកូនចៅ ឬក្មេងៗជំនាន់ក្រោយ ប្រាប់ថាយ៉ាងម៉េចទៅ ប្រាប់ពី តា ម៉ុក យ៉ាងម៉េច តា ម៉ុក មនុស្សសំខាន់យ៉ាងម៉េច?

ឡុត៖ ប្រាប់បានត្រឹមខ្ញុំស្គាល់គាត់ ដូចខ្ញុំនិយាយមិញចឹង ។

ដានី៖ ដូចខ្ញុំនិយាយមិញចឹង?

ឡុត៖ បាទ ។

ដានី៖ ចឹងចំពោះតា សុន សេន, តា ប៉ុល ពត, តា ខៀវ សំផន, តា នួន ជា ពូមានស្គាល់គាត់ដែរ?

ឡុត៖ ស្គាល់ឃើញតែមុខម្ដងៗទេ តា នួន ជា, តា ខៀវ សំផន ស្គាល់គាត់កាលដែលគាត់ចុះមក តែឲ្យស្គាល់ចិត្ត ស្គាល់ថ្លើមជិតស្និទ្ធ ធ្លាប់សុំអីដូចតា ម៉ុក អត់ដែលទេ។

ដានី៖ ចឹងស្គាល់តែ តា ម៉ុក ទេ ធ្លាប់សុំអីគាត់?

ឡុត៖ បាទ។

ដានី៖ ចឹងលោកពូពេលដែលយើងចុះមកឆាំ៩០ ពេលដែលចុះមកដំបូងឃើញទិដ្ឋភាពនៅអន្លង់វែងជាព្រៃ ឬជាស្រុកភូមិគេពីដើមមក?

ឡុត៖ អន្លង់វែងភូមិចាស់គេ លំទងក៏ភូមិចាស់។

ដានី៖ អន្លង់វែងភូមិចាស់ លំទងភូមិចាស់ មានតែពីរកន្លែងហ្នឹងទេ?

ឡុត៖ មានតា ដៀវ ត្រពាំងតាវ ឆ្ងាយៗពីគ្នា ទៅកើតនោះមានស្ទឹងផ្អាវ។

ដានី៖ មើលមុនដំបូងមានអន្លង់វែងភូមិចាស់ លំទងចាស់ភូមិចាស់ តា ដៀវភូមិចាស់ ត្រពាំងតាវភូមិចាស់ ផ្អាវភូមិចាស់ តែប៉ុណ្ណឹងទេ?

ឡុត៖ បាទ។

ដានី៖ ចឹងលោកមានដឹកថា មុនសម័យបីឆ្នាំ ឬក៏ក្នុងសម័យបីឆ្នាំនៅអន្លង់វែងហ្នឹងយ៉ាងម៉េចដែរមានមនុស្សរស់នៅមានជាស្រុកមានជាភូមិគេដែលអត់?

ឡុត៖ អានេះខ្ញុំក៏មិនដែលបានឃើញដែលសម័យនោះ និយាយទៅវាមាន។

ដានី៖ វាមាន?

ឡុត៖ បាទ។

ដានី៖ ពូមានដឹងពីរចនាសម្ព័ន្ធមានប្រជាជនរស់នៅមានគេរៀបចំជាភូមិជាស្រុកអីគេដែលអត់?

ឡុត៖ មុនមានទឹរួមស្រុកអន្លង់វែងហ្នឹងហើយ អន្លង់វែងជាស្រុកមួយ។

ដានី៖ ចឹងជាស្រុកមួយដែរ?

ឡុត៖ បាទ។

ដានី៖ កាលពីជំនាន់ណា?

ឡុត៖ កាលពីជំនាន់សម្ដេច សីហនុ។

ដានី៖ ជំនាន់សម្ដេចសីហនុ?

ឡុត៖ បាទ! សង្គមរាស្ត្រនិយម។

ដានី៖ លោកពូដឹងតាមរយៈអី?

ឡុត៖ ដឹងតាមរយៈប្រវត្តិសាស្ត្រ ការរៀនសូត្ររបស់យើង ។
ដានី៖ ចឹងថាគណៈស្រុកដំបូងឈ្មោះ អីដែលកាលហ្នឹង?
ឡុត៖ អត់ដឹងអត់ដែលស្គាល់ទេ ។
ដានី៖ ចឹងស្រុកអន្លង់វែងហ្នឹងមានតាំងពីជំនាន់សម្តេចឪមក?
ឡុត៖ បាទ ។
ដានី៖ ចឹងជំនាន់បីឆ្នាំដែលលោកពូមកតាមព្រំដែនហ្នឹង មានបានដើរឆ្លងកាត់អន្លង់វែងហ្នឹងទេ?
ឡុត៖ ខ្ញុំអត់ទេ អត់មានបានដើរឆ្លងកាត់ទេ ដូចខ្ញុំនិយាយពីខាងដើមមិញចឹង ដាច់៨១ខ្ញុំចាប់ពីសំរោងទៅខាងលិច ។
ដានី៖ ចឹងជំនាន់បីឆ្នាំនៅអន្លង់វែងយ៉ាងម៉េចដែរ មានប្រជាជនរស់នៅជាសហករណ៍ជាអីធ្វើការងារយ៉ាងម៉េចដែរ?
ឡុត៖ តាមខ្ញុំពូមាន ។
ដានី៖ មានដែរ?
ឡុត៖ ទើបតែដឹង៧៧ដឹង៧៨ពេលដែលជម្លៀសអ្នកស្រុកទៅនៅសំរោងខ្លះនៅក្រឡាញ់ខ្លះ ។
ដានី៖ ចឹងកាល៧៧-៧៨បានគេជម្លៀសទៅស្រុកលើ?
ឡុត៖ ដឹងថា៧៧-៧៨ មានអ្នកចាស់ស្រុកជម្លៀសទៅហ្នឹងទាំងអស់ ។
ដានី៖ ចឹងលោកពូដូចថាលោកពូចេញពីផ្ទះដាច់តែម្តងពីឆ្នាំ៧៥?
ឡុត៖ បាទ ។
ដានី៖ ដល់ឆ្នាំណាបានយើងទៅជួបផ្ទះមានទំនាក់ទំនងគ្រួសារឡើងវិញ?
ឡុត៖ ៩៩ ។
ដានី៖ ចឹង៩៩បានទៅលេងផ្ទះ?
ឡុត៖ បាទ ។
ដានី៖ ដឹងថាមានទំនាក់ទំនងជាមួយបងប្អូន មីងមាអីឡើងវិញ?
ឡុត៖ កាលហ្នឹងម៉ែឪស្លាប់មិនដឹងផង ។
ដានី៖ ចឹងពេលលោកពូទៅលេងផ្ទះលោកពូដែលនិយាយរឿងរ៉ាវដែលលោកពូចេញពីផ្ទះចេញគស៊ូរស់នៅអន្លង់វែងយ៉ាងម៉េចអីមានធ្លាប់និយាយប្រាប់ បងប្អូនមីងមានៅស្រុកកំណើតដែរ?
ឡុត៖ មាននិយាយខ្លះបងប្អូនមីងមាអី អ្នកជិតខាងសួរក៏ប្រាប់ ។
ដានី៖ មិនសូវនិយាយ ឬច្រើននិយាយ?

ឡូតៈ បើមកនេះទៅវាចង្អៀតដី នៅនោះដីវាទូលាយ ។

ដានីៈ ចឹងនៅក្នុងអារម្មណ៍លោកពូ តើលោកពូមានរឿងរ៉ាវអីដែលមិនចង់និយាយ ឬក៏និយាយប្រាប់គេមានទេ មានដែលអត់ក្នុងចិត្តពូក្នុងអារម្មណ៍របស់ពូ?

ឡូតៈ ទេ វាមិនមានរឿងរ៉ាវអីទេ ។

ដានីៈ ចឹងដូចជាក្រុមគ្រួសារលោកមុន ឬក៏បច្ចុប្បន្នអីហ្នឹង ដូចថាទំនាក់ទំនងក្នុងគ្រួសារលោកពូល្អូក ល្អឺនជាមួយគ្នាដែរ ឬក៏មានបញ្ហាអី?

ឡូតៈ អត់ទេ ចំពោះគ្រួសារខ្ញុំមិនដែលមានបញ្ហាអីទេ ទោះបីប្រពន្ធរាល់ថ្ងៃក៏មិនមានបញ្ហាអីដែរ ខ្ញុំនោះ ។

ដានីៈ ចឹងពូពេលយើងទំនេរ ឬជួបជុំក្រុមគ្រួសារ លោកពូភាគច្រើនយើងពិភាក្សាគ្នារឿងអីទៅ?

ឡូតៈ មានពិភាក្សារឿងធ្វើស្រែធ្វើចម្ការ រកស៊ី ។

ដានីៈ ពិភាក្សារឿងធ្វើស្រែចម្ការរឿងរកស៊ីទេ?

ឡូតៈ បាទ! ព្រោះសំខាន់ខ្ញុំគិតរាល់ថ្ងៃគិតរឿងជីវភាពរបស់យើង ។

ដានីៈ ចឹងពេលលោកពូចុះមកឆ្នាំ៩៩មក ដូចថាក្នុងភូមិរបស់លោកពូ ឬក្នុងឃុំ ឬមួយអន្លង់វែងទាំងមូល យើងមានគណបក្សនយោបាយប៉ុន្មាន ទៅដែលចូលមកទីនេះប្រកួតប្រជែងបោះឆ្នោត អីហ្នឹង?

ឡូតៈ មាន៥គណបក្សមានគណបក្សប្រជាជនយើង មានសមរង្ស៊ី មានហ៊ុនស៊ិនប៉ិច នរោត្តមសិទ្ធមនុស្ស ។

ដានីៈ ចឹងការប្រកួតប្រជែងនៅក្នុងអន្លង់វែងយើង នៅក្នុងភូមិពូភាគច្រើនបញ្ហាសំខាន់ការប្រកួតប្រជែងយ៉ាងម៉េចខ្លះទៅ?

ឡូតៈ មានតែយើងឃោសនាឲ្យអ្នកស្រុកបោះឆ្នោតឲ្យគេទៅ តែបើគិតទៅអ្នកចេញមុខនៅក្នុងភូមិរបស់ខ្ញុំនេះ មានខាងសិទ្ធមនុស្សនោះមានពីរនាក់ មានពីរគ្រួសារ ខាងសមរង្ស៊ីនោះមានមួយគ្រួសារដែលទេ គ្នា៦នាក់ ខាងនរោត្តមនោះ មានមួយគ្រួសារដែរ តែប្រពន្ធថាគេមិនតាមប្ដី ប្ដីទៅតែឯងទៅៗ ។

ដានីៈ ចឹងខាងគណបក្សផ្សេងៗមានតិចណាស់ មានតែមួយគ្រួសារពីរគ្រួសារអី ប៉ុណ្ណឹងទេ?

ឡូតៈ បាទ ។

ដានីៈ ចឹងដូចថា បញ្ហានយោបាយសំខាន់នៅក្នុងអន្លង់វែង ដូចថាមានឥទ្ធិពលមានអីសខាន់នៅអន្លង់វែងយើងមានបញ្ហាស់ទៅ?

ឡុតៈ បញ្ហានយោបាយសំខាន់ខ្លាំងណាស់ ។

ដានីៈ ចឹងបញ្ហានយោបាយ យើងមានឥទ្ធិពលសំខាន់ៗ នៅអន្លង់វែងយើងហ្នឹងគណបក្សទាំងអស់ហ្នឹង?

ឡុតៈ មានសំខាន់ដាងគេមានការគាំទ្រគណបក្សប្រជាជន គណបក្សប្រជាជនមានការអនុគ្រោះបង្រួបបង្រួមជាតិមានគោលការណ៍របស់គាត់ ឈ្នះៗៗៗគ្មានអ្នកណាចាញ់ គេឲ្យយើងរស់ហើយ យើងត្រូវដឹងគុណគេវិញ ។

ដានីៈ ចឹងគណបក្សប្រជាជនមានគោលការណ៍ច្បាស់លាស់?

ឡុតៈ បាទ ។

ដានីៈ ទនឹមហ្នឹងយើងមានចំណុចអសកម្មអីខ្លះដែលនៅក្នុងស្រុកភូមិពូ ដូចថាទាក់ទងនិងបញ្ហាមិនទាន់ដោះស្រាយបានល្អ មានដែលអត់?

ឡុតៈ នៅមានរឿងបញ្ហាដីធ្លី ។

ដានីៈ បញ្ហាដីធយ៉ាងម៉េចទៅ?

ឡុតៈ បញ្ហាដីធ្លីទៅប្រជុំថ្ងៃមុនខាងក្រុមហ៊ុន សុខាវិទ្ធនោះថាឲ្យដកចេញហើយអត់មានឲ្យវិនិយោគទេ តែនៅមានប៉ះពាល់ខាងដីសហគមន៍ តែនៅក្នុងភូមិខ្ញុំនេះវាអត់មានប៉ះពាល់ទេ តែវាមានប៉ះពាល់នៅខាងសំព័រ រហាល លំទងចាស់ ហ្នឹងមានជាមួយសហគមន៍ សំខាន់ដាងគេបីភូមិខាងនោះ ។

ដានីៈ ចឹងសំនួរចុងក្រោយ បើលោកពូជាអ្នកសរសេរប្រវត្តិសាស្រ្តនៅក្នុងស្រុកភូមិពូ នៅអន្លង់វែងយើងហ្នឹង លោកពូគិតថាយើងគួរតែបញ្ចូលស្អីទៅក្នុងសៀវភៅហ្នឹងដើម្បីឲ្យក្មេងៗជំនាន់ក្រោយ ដើម្បីឲ្យអ្នកសិក្សាស្រាវជ្រាវដែលគេបានអានទៅបានដឹងបានពួពីស្អីខ្លះទៅនៅសៀវភៅអន្លង់វែងយើង ។

ឡុតៈ មិនសូវដឹងទេ ។

ដានីៈ ចឹងបើសិនជាលោកពូជាអ្នកសរសេរដដែលព្រឹត្តិការណ៍សំខាន់ៗ អីខ្លះដែលយើងគួរតែសរសេរចូលទៅក្នុងសៀវភៅហ្នឹង ដើម្បីឲ្យក្មេងៗជំនាន់ក្រោយបានដឹង មានព្រឹត្តិការណ៍ដែលលោកពូធ្លាប់បានឆ្លងកាត់ ពូគិតថាយើងគួរតែសរសេរបញ្ចូនទុកជាប្រវត្តិសាស្រ្ត?

ឡុតៈ ដូចជាព្រឹត្តិការណ៍ តា ម៉ុក វាយជាមួយប៉ុល ពត អីហ្នឹងបញ្ចូលទៅ ។

ដានីៈ តា ម៉ុក វាយជាមួយ ប៉ុល ពត មានស្អីទៀតទៅ?

ឡុតៈ ការកសាង ស្នាដៃ តា ម៉ុក អី ប្រាប់ក្មេងក្រោយឲ្យវាបានដឹង ។

ដានី: ចឹង តា ម៉ុក គាត់បានកសាងស្នាដៃអីខ្លះទៅ បន្សល់ទុកមកដល់សព្វថ្ងៃយើងនៅតំបន់អន្លង់វែងយើងហ្នឹង?

ឡុត: ទុកសព្វថ្ងៃនេះដូចជាស្ពានយើងអូរជីកហាង ទំនប់ក៏របស់គាត់ ផ្លូវក្រហមនេះជារបស់គាត់ដែរ សុទ្ធតែផ្លូវរបស់គាត់ដែរ ។

ដានី: ផ្លូវណា?

ឡុត: អាផ្លូវចេញនេះ ផ្លូវយាយវៃនេះ ។

ដានី: ផ្លូវមកភូមិលោកពូ ផ្លូវមកលំទងចាស់ហ្នឹង?

ឡុត: បាទ! ចាក់គ្រួសក្រហមដែលតើ ។

ដានី: គាត់បានកសាងបាន ស្ពាន បានទំនប់ បានផ្លូវ?

ឡុត: ផ្លូវទៅសាលាស្រុកក៏គាត់ដែលហើយដល់ក្រោយមកគេចាក់កៅស៊ូលើផ្លូវគាត់ ហើយគាត់បានកសាងទំនប់ថ្មី ។

ដានី: ចឹងគាត់លើកទំនប់ថ្មីនេះទៀត?

ឡុត: បាទ ។

ដានី: មានអីទៀត?

ឡុត: ទៅម្តុំខាងស្រះឈូក មានទំនប់លើទំនប់អីនោះ មានមន្ទីរពេទ្យសព្វថ្ងៃ សាលារៀនទៀត ។

ដានី: មានមន្ទីរពេទ្យ សាលារៀន ទំនប់ ផ្លូវ គាត់កសាងបានច្រើនដែរ?

ឡុត: បាទ ។

ដានី: ចឹងក្នុងនាមជាបុគ្គលពូ ឬក៏តំណាងឲ្យប្រជាជននៅក្នុងភូមិពូ លោកពូមានការសង្ឃឹមស្អីខ្លះពីសៀវភៅប្រវត្តិសាស្ត្រដែលពួកខ្ញុំកំពង់តែរៀបរាង កំពង់តែចង់សរសេរនេះ ជាបុគ្គល ឬតំណាងឲ្យសហគមន៍ពូ លោកពូសង្ឃឹមស្អីខ្លះទៅ?

ឡុត: ពីការតស៊ូ មិនសូវយល់ដែលត្រង់នេះ មិនដឹងមានអីខ្លះត្រូវសរសេរ ។

ដានី: ចឹងលោកពូខ្ញុំដូចជាអស់សំនួរត្រូវសួរនាំលោកពូទៀតហើយ ចឹងលោកពូមានអីចង់បញ្ជាក់បន្ថែមនូវអ្វីដែលខ្ញុំមិនបានសួរនាំលោកពូទៀតទេ?

ឡុត: ដូចជាអត់មានទេ ។

ដានី: ចឹងខ្ញុំអរគុណលោកពូច្រើនដែលបានផ្តល់បទសម្ភាសន៍ជាមួយខ្ញុំជាងមួយម៉ោងនេះលោកពូខ្ញុំអរគុណច្រើនលោកពូ ។

ឡុត: បាទ ។

**«ចប់»**